# តើអ្នកចូលឥស្លាមយ៉ាងដូចម្ដេច?

# كيفَ تدخل في الإسلام؟

ចងក្រងដោយ

បណ្ឌិត **ម៉ូហាំម៉ាត់ស៊ូឡៃម៉ាន អាល់អាស្ហការ**



បោះពុម្ពលើកទី១
២០១៥

# كيف تدخل في الإسلام؟

**ដោយ** បណ្ឌិត ម៉ូហាំម៉ាត់ស៊ូឡៃម៉ាន អាល់អាស្គារ

المؤلف/د.محمد سليمان الأشقر

អង្គការវប្បធម៌ អារ៉ាប់ធម៌កម្ពុជា_អារ៉ាប់
Cambodia Arab Cultural Civilizational Organization

សមាគមសប្បុរសធម៌ដើម្បីអភិវឌ្ឍន៍កម្ពុជា
جمعية البركة الخيرية في كمبوديا

# តើអ្នកចូលអ៊ីស្លាមយ៉ាងដូចម្តេច ?

# كيف تدخل في الإسلام؟

**ចងក្រងដោយបណ្ឌិត ៖**

**មូហាំម៉ាត់សូឡៃម៉ាន អាល់អាស្គការ**

# មាតិកា

ជំពូកទី១: អារម្ភកថា........................................................................3
ជំពូកទី២: ឥស្លាម.............................................................................6
ជំពូកទី៣: ការធ្វើដំណើរដ៏មហិមា.......................................................9
ជំពូកទី៤: តើអ្នកត្រូវថាអ្វីខ្លះនៅពេលអ្នកប្រកាសខ្លួនចូលឥស្លាម..........10
ជំពូកទី៥: តើអ៊ីស្លាមគឺជាអ្វី..............................................................12
ជំពូកទី៦: ការជឿចំពោះអល់ឡោះ.......................................................13
ជំពូកទី៧: ជំនឿចំពោះទេវតា.............................................................16
ជំពូកទី៨: ជំនឿចំពោះគម្ពីរ៧ដែលគេបញ្ចុះពីលើមេឃ...........................18
ជំពូកទី៩: ជំនឿចំពោះពួកព្យាការី.......................................................20
ជំពូកទី១០: ជំនឿចំពោះថ្ងៃបរលោក...................................................23
ជំពូកទី១១: ការគោរពសក្ការៈ...........................................................25
ជំពូកទី១២: ពាក្យសច្ចាទាំងពីរ...........................................................26
ជំពូកទី១៣: ការថ្វាយបង្គំ....................................................................27
ជំពូកទី១៤: ការជម្រះសម្អាត...............................................................28
ជំពូកទី១៥: តើយើងថ្វាយបង្គំយ៉ាងដូចម្តេច?........................................30
ជំពូកទី១៦: ការបរិច្ចាគទ្រព្យ..............................................................34
ជំពូកទី១៧: បួស (ការតមអាហារ).......................................................37
ជំពូកទី១៨: ការធ្វើបុណ្យហាជ្ជ...........................................................41
ជំពូកទី១៩: តើអ្នកអភិវឌ្ឍអ៊ីស្លាមរបស់អ្នកយ៉ាងដូចម្តេច?....................45
ជំពូកទី២០: តើអ្នករក្សាអ៊ីស្លាមរបស់អ្នកយ៉ាងដូចម្តេច? ....................48
ជំពូកទី២១: តើអ្នកអំពាវនាវអ្នកដទៃឱ្យចូលអ៊ីស្លាមយ៉ាងដូចម្តេច?.......51
ជំពូកទី២២: ប្រការដែលគេហាមឃាត់ ..............................................54

ជំពូកទី២៣: អាវលីយ៉ាកររបស់អល់ឡោះ..........................................57
ជំពូកទី២៤: សីលធម៌ និងសុជីវធម៌អ៊ីស្លាម..........................................60
ជំពូកទី២៥: ការរំឭក និង ការបួងសួង..........................................61
ជំពូកទី២៦: ស្ត្រីមូស្លីម..........................................63
ជំពូក អាល់ហ្វាទីហះ..........................................65
ជំពូក អាល់អើសរី..........................................67
ជំពូក អាល់ម៉ាអ៊ូន..........................................68
ជំពូក អាល់អៀខឡោស..........................................69
ជំពូក អាល់ការសើរ..........................................70
ជំពូក អាល់ហ្វាឡាក..........................................71
ជំពូក អាន់ណាស..........................................72
អាត់តាស្ហះហ៊ុដ..........................................73

﴿ يَٰٓأَيُّهَا ٱلنَّاسُ ٱعۡبُدُواْ رَبَّكُمُ ٱلَّذِي خَلَقَكُمۡ وَٱلَّذِينَ مِن قَبۡلِكُمۡ لَعَلَّكُمۡ تَتَّقُونَ ﴾ البقرة: ٢١

មានន័យថា៖ «ឱមនុស្សទាំងឡាយ! ចូរពួកអ្នកគោរពសក្ការៈចុះចំពោះព្រះជាម្ចាស់របស់ពួកអ្នក ដែលបានបង្កើតពួកអ្នក ហើយនិងពួកអ្នកដែលមុនៗពួកអ្នក សង្ឃឹមថាពួកអ្នកនឹងកោតខ្លាច»។ អំពាវនាវដល់បងប្អូនគ្រប់រូបដើម្បីមករួមជាមួយនឹងក្បួនដំណើររបស់ពួកអ្នកមានជំនឿឆ្ពោះទៅកាន់អល់ឡោះ

﴿ وَمَن يُطِعِ ٱللَّهَ وَٱلرَّسُولَ فَأُوْلَٰٓئِكَ مَعَ ٱلَّذِينَ أَنۡعَمَ ٱللَّهُ عَلَيۡهِم مِّنَ ٱلنَّبِيِّـۧنَ وَٱلصِّدِّيقِينَ وَٱلشُّهَدَآءِ وَٱلصَّٰلِحِينَۚ وَحَسُنَ أُوْلَٰٓئِكَ رَفِيقٗا ٦٩ ﴾ النساء: ٦٩

មានន័យថា៖ «អ្នកណាដែលគោរពប្រតិបត្តិចំពោះអល់ឡោះនិងអ្នកនាំសារ។ ដូច្នេះពួកគេស្ថិតនៅជាមួយនឹងពួកអ្នកដែលទ្រង់បានប្រទានពរជ័យដល់ពួកគេនៃពួកអ្នកនាំសារ ពួកអ្នកដែលជឿជាក់ ពួកអ្នកដែលពលីជីវិតក្នុងនាមសាសនា និងពួកអ្នកដែលធ្វើអំពើល្អ ហើយពួកគេជាគូកនដ៏ល្អប្រសើរជាទីបំផុតនៅក្នុងឋានសួគ៌»។

# ជំពូកទី១

## អារម្ភកថា

1. ចូរអ្នកក្រឡេកមើលទៅលើអ្វីៗដែលនៅជុំវិញអ្នក នៅលើផែនដី វត្ថុ រុក្ខជាតិ សត្វពាហនៈ សត្វស្លាប សត្វល្អិត និងត្រីទាំងឡាយ...។
2. តើអ្នកមិនឃើញទេឬ អ្វីទាំងនោះមានក្រឹត្យក្រមដ៏សុក្រឹតឥតខ្ចោះ ដែលគ្រប់គ្រងលើជីវិតរស់នៅ និងទិសដៅរបស់សភាវសត្វលោកទាំងនោះ ?
3. ចូរអ្នកក្រឡេកមើលទៅកាន់រាល់អ្វីៗដែលនៅខាងលើអ្នកក្នុងលំហ មាន ព្រះអាទិត្យ ព្រះចន្ទ ផ្កាយ ពពក ខ្យល់...តើវាមិនបានដើរតាមក្រឹត្យក្រមយ៉ាងលម្អិត ហើយបំពេញសេវាកម្មបម្រើដល់ការរស់នៅរបស់យើងនៅលើផែនដីនេះទេឬ ?
4. ចូរពិចារណាលើខ្លួនអ្នក អវយវៈខ្លួនប្រាណ និងប្រព័ន្ធរាងកាយរបស់អ្នកដ៏ច្រើន និងសែនអស្ចារ្យ ហេតុអ្វីវាដំណើរការដោយសហការគ្នា ដើម្បីរក្សាការរស់នៅរបស់អ្នកប្រកបដោយសុខដុមរមនា ?
5. តើអ្នកណាជាអ្នកបង្កើតអច្ឆរិយៈទាំងនេះ ? តើអ្នកណាជាអ្នកកំណត់ក្រឹត្យក្រមរបស់វា ? តើអ្នកណាជាអ្នកដែលត្រួតត្រា និងបញ្ជាចក្រវាឡដ៏ធំសម្បើមអស្ចារ្យនិងមហាស្មុគស្មាញនេះ ?
6. គ្មានអ្នកណាម្នាក់ហ៊ានអះអាងថាខ្លួនគេបានបង្កើតអ្វីមួយនៃសភាវៈទាំងនេះ ឬក៏មានសមត្ថភាពក្នុងបង្កើតអ្វីមួយសូម្បីមួយសសៃសក់!!
7. ពិតប្រាកដណាស់ អ្នកដែលបង្កើតឱ្យមានអ្វីៗនៅលើលោក និងគ្រប់គ្រងលើការងារនេះគឺតែម្នាក់គត់។ ប្រសិនជាមានអ្នកណាផ្សេងទៀត

ក្រៅពីម្នាក់នោះគឺ ច្បាស់ជាក្រឹត្យក្រមទាំងឡាយនៅក្នុងចក្រវាឡ និងនៅលើមេឃនឹងត្រូវវិនាសជាមិនខាន។ ម្នាក់នោះគឺជា (ព្រះជាម្ចាស់ដ៏ពិតប្រាកដ)។

8. ជាការសមហេតុសមផល ដែលយើងត្រូវទទួលស្គាល់នូវការពិតនេះ យើងស្គាល់ព្រះជាម្ចាស់ដែលជាអ្នកបង្កើតយើង។ ជាព្រះជាម្ចាស់របស់យើង យើងដឹងគុណចំពោះទ្រង់ដែលបានប្រទានពរជ័យនេះមកដល់យើង។ លើសពីនេះ យើងត្រូវប្រគល់ខ្លួនយើង ជីវិតរស់នៅរបស់យើងសម្រាប់ក្តីចង្អុលបង្ហាញរបស់ទ្រង់ដ៏មហាករុណាប្រកបដោយគតិបណ្ឌិតនិងក្តីមេត្តា។
9. ម្ចាស់របស់យើងបានប្រទានដល់យើងនូវប្រាជ្ញាសម្រាប់គិតពិចារណានិងសេរីភាពដើម្បីជ្រើសរើសផ្លូវដ៏ត្រឹមត្រូវ។
10. អល់ឡោះបានបង្ហាញប្រាប់យើងនូវផ្លូវដ៏ត្រឹមត្រូវតាមរយៈបណ្តាអ្នកនាំសាររបស់ទ្រង់ ដែលបញ្ចប់ត្រឹមអ្នកនាំសារឈ្មោះមូហាំម៉ាត់ ដែលជាអ្នកនាំសារចុងក្រោយបង្អស់ ហើយអល់ឡោះបានបង្ហាញប្រាប់យើងនូវផ្លូវដ៏ត្រឹមត្រូវតាមរយៈបណ្តាគម្ពីៗរបស់ទ្រង់ ដែលបញ្ចប់ដោយគម្ពីរអាល់គួរអាន។
11. ដូច្នេះឥឡូវនេះ នៅខាងមុខយើងមានផ្លូវពីរៈផ្លូវទី១នាំយើងទៅកាន់ភាពសុខសាន្តទាំងក្នុងលោកីយ៍ និងបរលោកនោះគឺសាសនាអ៊ីស្លាម។
12. ផ្លូវទី២នាំយើងទៅកាន់វាសនាអភ័ព្វនិងការខាតបង់នៅក្នុងលោកីយ៍ ហើយនឹងត្រូវគេធ្វើទារុណកម្មជាអមតៈនៅថ្ងៃបរលោក។

**ជម្រើសស្ថិតនៅក្នុងដៃរបស់យើងទាំងអស់គ្នា ដូច្នេះ តើយើងនឹងជ្រើសរើសយកអ្វី?**

សូមអល់ឡោះជាម្ចាស់ទ្រង់បង្ហាញផ្លូវដ៏ត្រឹមត្រូវដល់យើង( សូមទ្រង់មេត្តាទទួលយកការបួងសួងនេះផងចុះ )។

# ជំពូកទី២
# អ៊ីស្លាម

ហេតុអ្វី? សម្រាប់អ្នកណា? ពេលណា? អ៊ីស្លាម...ហេតុអ្វី?

1. ព្រោះអ៊ីស្លាមជាសាសនារបស់ពួកព្យាការីដែលអល់ឡោះទ្រង់សព្វព្រះទ័យទទួលស្គាល់ជាសាសនាសម្រាប់មនុស្សលោកទាំងអស់។
2. ព្រោះអ៊ីស្លាមជាសាសនារបស់ពួកព្យាការីទាំងឡាយ តាំងពីព្យាការីអាដាំ រហូតដល់ព្យាការី មូហាំម៉ាត់(សូមសេចក្ដីសុខសន្តិភាពកើតមានចំពោះពួកគាត់ទាំងអស់គ្នា)។
3. ព្រោះអ៊ីស្លាមជាសាសនាចុងក្រោយក្នុងចំនោមសាសនាដែលគេបញ្ចុះពីលើមេឃមក។
4. អ្នកនាំសារសាសនាអ៊ីស្លាម គឺជាអ្នកនាំសារចុងក្រោយបង្អស់ក្នុងបណ្ដាអ្នកនាំសារទាំងឡាយរបស់អល់ឡោះ។
5. គម្ពីរអាល់គួរអាន ជាគម្ពីរចុងក្រោយបង្អស់ក្នុងចំណោមគម្ពីរៗដែលគេបញ្ចុះពីលើមេឃមក។
6. អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿أَفَغَيْرَ دِينِ ٱللَّهِ يَبْغُونَ وَلَهُۥٓ أَسْلَمَ مَن فِى ٱلسَّمَٰوَٰتِ وَٱلْأَرْضِ طَوْعًا وَكَرْهًا وَإِلَيْهِ يُرْجَعُونَ ﴿٨٣﴾﴾ آل عمران: ٨٣

មានន័យថា៖ «តើសាសនាផ្សេងពីសាសនារបស់អល់ឡោះឬដែលពួកគេស្វែងរក? សម្រាប់ទ្រង់គឺ អ្នកដែលនៅលើមេឃនិងនៅលើផែនដីព្រមចុះចូលគោរពចំពោះទ្រង់ទាំងស្ម័គ្រចិត្តនិងបង្ខំ ហើយពួកគេទាំងអស់នឹងវិលត្រឡប់ទៅរកទ្រង់វិញ»។

## **តើអ៊ីស្លាម...សម្រាប់អ្នកណា?**

7. សម្រាប់រាល់អ្នកដែលអល់ឡោះប្រទានដល់រូបគេនូវជីវិតរស់នៅ និងប្រាជ្ញាស្មារតី។
8. សម្រាប់រាល់អ្នកដែលមានចក្ខុ(ភ្នែក)ពីរមើលឃើញអ្វីដែលអល់ឡោះបានប្រទានជូន។
9. សម្រាប់អ្នកណាដែលមានត្រចៀកស្តាប់ព្រះបន្ទូលរបស់អល់ឡោះ។
10. សម្រាប់រាល់អ្នកដែលមានប្រាជ្ញាយល់ដឹងពីភស្តុតាងនិងព្រះបន្ទូលរបស់អល់ឡោះ។
11. សម្រាប់រាល់អ្នកដែលមានបេះដូងមានចលនាដោយក្តីស្រលាញ់ដឹងគុណនិងអរគុណចំពោះទ្រង់។
12. សម្រាប់អ្នក សម្រាប់ខ្ញុំ សម្រាប់រាល់អ្នកដែលអល់ឡោះបើកចំបេះដូងរបស់គេសម្រាប់ក្តីជំនឿ។

## **តើអ៊ីស្លាម...ពេលណា?**

13. ពេលឥឡូវនេះ...នៅថ្ងៃនេះ...មុនថ្ងៃស្អែក...
14. ចូរអ្នកគោរពចំពោះអ្នកដែលជំរុញលើកទឹកទៅរកក្តីជំនឿ...
15. ពិតណាស់ជាឱកាសក្នុងឆាកជីវិតរបស់អ្នក...
16. ជាឱកាសមាសជួនកាលមិនអាចឆ្លងកាត់ចិត្តរបស់អ្នកជាលើកទីពីរនោះឡើយ...។
17. ចូរអ្នកឆ្លើយតបនឹងការអំពាវនាវរបស់អល់ឡោះ...ពិតណាស់ទ្រង់កំពុងហៅអ្នក

18. ទ្រង់បានមានព្រះបន្ទូលថា៖

﴿ فَإِلَٰهُكُمْ إِلَٰهٌ وَٰحِدٌ فَلَهُۥٓ أَسْلِمُوا۟ ۗ وَبَشِّرِ ٱلْمُخْبِتِينَ ﴿٣٤﴾ ﴾ الحج: ٣٤

មានន័យថា៖ «ដូច្នេះ ព្រះម្ចាស់របស់ពួកអ្នកគឺមានតែមួយគត់ ចូរពួកអ្នកប្រគល់ខ្លួនគោរពសក្ការៈចំពោះទ្រង់ ហើយចូរផ្តល់ដំណឹងរីករាយដល់ពួកអ្នកដែលបន្ទាបខ្លួនគោរព»។

# ជំពូកទី៣
# ការធ្វើដំណើរដ៏ធំមហិមា

1. នៅពេលដែលអ្នកព្រមទទួលថា អ៊ីស្លាមគឺជាសាសនាពិត។
2. ដូច្នេះចូរអ្នកស្វែងរកបន្ថែមតាមគ្រឹះស្ថានផ្លូវការរបស់អ៊ីស្លាមសំខាន់ៗ ដូចជាមជ្ឈមណ្ឌលអ៊ីស្លាម វិហារអ៊ីស្លាម ឬអង្គការអ៊ីស្លាមនានា។
3. ចូរទំនាក់ទំនងជាមួយនឹងអ្នកទទួលខុសត្រូវនៅទីនោះ ហើយប្រាប់គេពីការចង់ចូលសាសនាអ៊ីស្លាមរបស់អ្នក។
4. គាត់នឹងសួរអ្នកនូវសំនួរខ្លះៗ ដើម្បីដឹងពីកម្រិតនៃការចូលអ៊ីស្លាមរបស់អ្នក។
5. បើសិនជាអ្នកបានអានសារនេះ មុននឹងអ្នកទៅជួបគាត់ អ្នកអាចឆ្លើយនឹងសំនួររបស់គាត់បាន។
6. ក្នុងថ្ងៃដែលអ្នកសំរេចចិត្តថា អ្នកនឹងប្រកាសខ្លួនចូលអ៊ីស្លាម ដូច្នេះមុននឹងអ្នកធ្វើដំណើរទៅកាន់កន្លែងណាត់ជួបដ៏សំខាន់នោះចូរអ្នកងូតទឹកសម្អាតខ្លួន ដោយនឹកក្នុងចិត្តថា ខ្ញុំចូលសាសនាអ៊ីស្លាម ហើយជាការប្រសើរបំផុត បើសិនជាអ្នកបានកោរសក់និងស្លៀកសំលៀកបំពាក់ណាដែលអ្នកគិតថាវាល្អជាងគេក្នុងចំណោមសំលៀកបំពាក់របស់អ្នក ហើយអាចលាប និងបាញ់ទឹកអប់ឱ្យក្រអូបផងដែរ។

# ជំពូកទី៤
## តើអ្នកត្រូវថាអ្វីខ្លះនៅពេលអ្នកប្រកាសខ្លួនចូលអ៊ីស្លាម?

1. គ្រប់គ្រាន់សម្រាប់ការចូលអ៊ីស្លាមដោយគ្រាន់តែពោលថា ៖
2. ( أشهد أن لا إله إلا الله ) មានន័យថា៖ « ខ្ញុំធ្វើសច្ចាថា ពិតប្រាកដណាស់ គ្មានទេព្រះម្ចាស់ដែលគោរពសក្ការៈយ៉ាងពិតប្រាកដលើកលែងតែអល់ឡោះ»។
3. (وأشهد أن محمدا رسول الله) មានន័យថា ៖ «ហើយខ្ញុំសូមសច្ចាថាពិតប្រាកដណាស់មូហាំម៉ាត់ជាអ្នកនាំសាររបស់អល់ឡោះ»។
4. ( وأشهد أن عيسى عبد الله ورسوله ) មានន័យថា ៖ «ហើយខ្ញុំសូមសច្ចាទៀតថា ពិតប្រាកដណាស់ ព្យាការីអ៊ីសា( យេស៊ូ )គឺជាខ្ញុំបម្រើរបស់អល់ឡោះ និងជាអ្នកនាំសាររបស់ទ្រង់ )។
5. (برئت من كل دين يخالف دين الإسلام) មានន័យថា៖( ខ្ញុំលែងពាក់ព័ន្ធជាមួយនឹងសាសនាដែលផ្សេងពីសាសនាអ៊ីស្លាម )។
6. ប៉ុន្តែជាការល្អណាស់ បើសិនជាអ្នកសូត្រថា៖ ខ្ញុំជឿចំពោះអល់ឡោះ ពួកទេវតារបស់ទ្រង់ គម្ពីរៗរបស់ទ្រង់ ពួកអ្នកនាំសាររបស់ទ្រង់ ជឿចំពោះថ្ងៃបរលោក ហើយជឿចំពោះសំណាងល្អនិងសំណាងអាក្រក់មកពីអល់ឡោះ។
7. ខ្ញុំសន្យាចំពោះអល់ឡោះថា ខ្ញុំមិនយកអ្វីមួយមកគោរពចូលរួមជាមួយនឹងទ្រង់ជាដាច់ខាត។
8. ខ្ញុំប្រតិបត្តិសឡាត( ថ្វាយបង្គំ )
9. ខ្ញុំបរិច្ចាគទ្រព្យ
10. ខ្ញុំមិនលួចប្លន់

11. ខ្ញុំមិនប្រព្រឹត្តអំពើផិតក្បត់ជាមួយនឹងស្ត្រីផ្សេងៗ។
12. ខ្ញុំមិនសំលាប់ជីវិតដែលគេដាក់ច្បាប់បំរាម។
13. ខ្ញុំមិនប្រព្រឹត្តល្មើសនឹងអល់ឡោះ។
14. ការសសើរសម្រាប់អល់ឡោះ ដែលទ្រង់បានប្រទានដល់ខ្ញុំឱ្យស្គាល់នូវជំនឿ។
15. បញ្ជាក់៖ អ្នកដែលទទួលខុសត្រូវ គប្បីសុំបួងសួងពីអល់ឡោះឱ្យអ្នកដែលមកប្រកាសខ្លួនចូលអ៊ីស្លាមដែលកំពុងតែឈរនៅចំពោះមុខគេនោះដោយបួងសួងថា ៖

(غفرالله لي ولك ، وتقبّل الله مني ومنك ، اللهم اجعله مع الذين أنعت عليهم من النبيين والصديقين ، والشهداء ، والصالحين ، وحَسُن أولئك رفيقا)،

មានន័យថា៖ «សូមអល់ឡោះលើកលែងទោសដល់រូបខ្ញុំនិងអ្នក ហើយអល់ឡោះទ្រង់ទទួលយកអំពីរូបខ្ញុំនិងអ្នក ឱអល់ឡោះសូមទ្រង់បង្កើតរូបគេផងចុះក្នុងចំណោមពួកអ្នក ដែលទ្រង់បានប្រទានដល់ពួកគេនៃពួកព្យាការី ពួកអ្នកជឿជាក់ ពួកអ្នកពលីដើម្បីសាសនា ពួកអ្នកធ្វើអំពើល្អ ហើយល្អណាស់ដែលបានពួកគេជាគូកននោះ»។

# ជំពូកទី៥
# តើអ៊ីស្លាមគឺជាអ្វី?

1. អ៊ីស្លាមមាន៣ប្រការ សំដី ការជឿជាក់ក្នុងចិត្ត និងការអនុវត្ត។
2. សំដី៖ អ្វីដែលបានគេបញ្ជាក់ប្រាប់អ្នកក្នុងជំពូកមុន។
3. ការជឿជាក់ក្នុងចិត្ត ៖ គឺការជឿចំពោះអល់ឡោះ ទេវតា គម្ពីរៗ ដែលគេប្រទានចុះមកពីលើមេឃ ពួកអ្នកនាំសារ ហើយនិងថ្ងៃបរលោក។
4. ការអនុវត្ត ៖ ដូចជាការបួស ការថ្វាយបង្គំ ការបរិច្ចាគទ្រព្យ ការទៅធ្វើបុណ្យធម្មយាត្រា (ហាជ្ជ)នៅទីក្រុងម៉ឹក្កះ។

# ជំពូកទី៦
# ការជឿចំពោះអល់ឡោះ

1. ពួកយើងមានជំនឿថា ពិតប្រាកដណាស់ អល់ឡោះគឺជាព្រះម្ចាស់តែមួយ ទ្រង់ជាព្រះញជាម្ចាស់របស់យើង និងជាព្រះជាម្ចាស់នៃអ្វីៗគ្រប់យ៉ាង។
2. អល់ឡោះទ្រង់ជាអ្នកបង្កើតអ្វីគ្រប់យ៉ាង។
3. រាល់អ្វីៗដែលផ្សេងអំពីទ្រង់គឺជាសភាវសត្វលោកដែលទ្រង់បានបង្កើតជាខ្ញុំរបស់អល់ឡោះ គ្មានសិទ្ធិអំណាចអ្វីរួមជាមួយនឹងអល់ឡោះឡើយ។
4. សូម្បីពួកទេវតា ពួកព្យាការី ពួកគេទាំងនោះក៏ជាខ្ញុំបម្រើរបស់អល់-ឡោះផងដែរ។
5. ក្នុងចំណោមពួកគេមានដូចជា អ៊ីសា(យេស៊ូ) មូហាំម៉ាត់ ពួកគេទាំងពីរគ្មានសិទ្ធិអំណាចអ្វីក្លាយជាព្រះជាម្ចាស់នោះឡើយ។
6. ពួកយើងជឿជាក់ក្នុងចិត្តថា ពិតប្រាកដណាស់ អល់ឡោះ ទ្រង់រស់ជាអមតៈ ទ្រង់ជាព្រះដំបូងបង្អស់គ្មានទីចាប់ផ្ដើម ទ្រង់ជាព្រះចុងក្រោយបង្អស់គ្មានទីបញ្ចប់។
7. ទ្រង់មហាឮ ឮរាល់សម្លេងទាំងឡាយ ហើយទ្រង់មហាឃើញ ឃើញរាល់អ្វីៗទាំងអស់។
8. ទ្រង់គឺមហាសណ្ដោស មហាអាណិតស្រលាញ់ មានអានុភាពលើអ្វីគ្រប់យ៉ាង។
9. ទ្រង់មានព្រះនាមៗដ៏ល្អប្រពៃ និងមានលក្ខណៈសម្បត្តិដ៏ខ្ពង់ខ្ពស់ជាទីបំផុត។

10. ពួកយើងជឿជាក់ក្នុងចិត្តថា ពិតប្រាកដណាស់ អល់ឡោះទ្រង់បានបង្កើតពួកយើងពីភាពគ្មាន

11. ទ្រង់បានបង្កើតពួកយើងឱ្យមានរូបសម្បត្តិលក្ខណៈដ៏ល្អប្រពៃជាទីបំផុត។

12. ទ្រង់បានប្រទានដល់ពួកយើងនូវរាល់ពរជ័យទាំងឡាយ ហេតុដូច្នេះគេមិនអនុញ្ញាតឱ្យយើងគោរពសក្ការៈចំពោះអ្នកណាម្នាក់ផ្សេងក្រៅពីទ្រង់ឡើយ សូម្បីអ្នកនោះជាស្តេចដ៏ខ្ពង់ខ្ពស់ ឬក៏ជាអ្នកនាំសារដែលគេបញ្ជូនមកក៏ដោយ។

13. អ្នកណាថ្វាយបង្គំចំពោះអ្នកផ្សេងក្រៅពីអល់ឡោះ ឬ អោនក្បាលសំពះក្រៅពីអល់ឡោះ ឬសំឡេះសត្វថ្វាយជូនអ្វីផ្សេងក្រៅពីអល់ឡោះក្នុងបំណងគោរពបូជា និងលើកតម្កើងអ្នកនោះ ដូច្នេះគេគឺជាអ្នកប្រឆាំងនឹងអល់ឡោះ ហើយអ្នកនោះមិនមែនជាអ្នកអ៊ីស្លាមទេ បើទោះជាគេពោលពាក្យសច្ចាសាក្សីក៏ដោយ។

14. អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿ قُلْ إِنَّ صَلَاتِي وَنُسُكِي وَمَحْيَايَ وَمَمَاتِي لِلَّهِ رَبِّ الْعَالَمِينَ ﴿١٦٢﴾ لَا شَرِيكَ لَهُ ۖ وَبِذَٰلِكَ أُمِرْتُ وَأَنَا أَوَّلُ الْمُسْلِمِينَ ﴿١٦٣﴾ ﴾ الأنعام: ١٦٢ - ١٦٣

មានន័យថា៖«មូហាំម៉ាត់ចូរអ្នកពោលចុះ ពិតណាស់ ការថ្វាយបង្គំរបស់ខ្ញុំ ការសំឡេះសត្វបូជារបស់ខ្ញុំ ការរស់នៅរបស់ខ្ញុំ ការស្លាប់របស់ខ្ញុំ ដើម្បីអល់ឡោះជាម្ចាស់នៃសកលលោកទាំងមូលគ្មានទេដៃគូរួមចំណែកសម្រាប់ទ្រង់ក្នុងការគោរពសក្ការៈ។ ទាំងនេះគឺជាអ្វីដែលគេបង្គាប់ប្រើមកចំពោះខ្ញុំ ហើយខ្ញុំជាអ្នកមូស្លីមដំបូងបង្អស់)។

15. អ៊ីស្លាម គឺជាសាសនាដែលមានគោលជំនឿលើព្រះតែមួយ ក្នុងសាសនា
16. អ៊ីស្លាមពុំមានម្ចាស់ពីរដូចពួកអ្នកគោរពភ្លើង ហើយគ្មានព្រះបីអង្គដូចពួកគ្រិស្ទាននោះដែរ។ អល់ឡោះគឺជាព្រះតែមួយ គ្មានអ្នកណាម្នាក់ជាដៃគូសម្រាប់ទ្រង់ក្នុងការគ្រប់គ្រង ហើយក៏គ្មានផងដែរក្នុងការ
17. កាត់ក្តី សម្រាប់អល់ឡោះគឺមានព្រះនាមៗដ៏មហាល្អប្រពៃ និងមានលក្ខណៈសម្បត្តិមហាខ្ពង់ខ្ពស់។
18. អល់ឡោះបានមានបន្ទូលថា៖

﴿ قُلْ هُوَ ٱللَّهُ أَحَدٌ ١ ٱللَّهُ ٱلصَّمَدُ ٢ لَمْ يَلِدْ وَلَمْ يُولَدْ ٣ وَلَمْ يَكُن لَّهُۥ كُفُوًا أَحَدٌۢ ٤ ﴾ الإخلاص: ١ - ٤

មានន័យថា៖ «មូហាំម៉ាត់ ចូរអ្នកមានប្រសាសន៍ចុះថា ទ្រង់គឺអល់ឡោះតែមួយគត់។ អល់ឡោះជាទីពំនឹង ទ្រង់មិនប្រសូត ហើយក៏គ្មានអ្នកណាម្នាក់បង្កើតទ្រង់ដែរ។ គ្មាននរណាម្នាក់ប្រៀបផ្ទឹមនឹងទ្រង់បានឡើយ)។

# ជំពូកទី ៧
# ជំនឿចំពោះពួកទេវតា

1. យើងមានជំនឿថាសម្រាប់អល់ឡោះគឺមានពួកទេវតាដែលអល់ឡោះបានបង្កើតដើម្បីឱ្យពួកគេគោរពសក្ការៈចំពោះទ្រង់ និងបម្រើកិច្ចការរបស់ទ្រង់។ ពួកគេជាទូតនាំសាររវាងទ្រង់ជាមួយនឹងពួកព្យាការីទាំងឡាយ។
2. ទេវតាទាំងនោះមានឈ្មោះ ជីព្រីលល ជាអ្នកនាំវ៉ាហ៊ី(ព្រះបន្ទូល) មកឱ្យព្យាការីរបស់យើងមូហាំម៉ាត់(សូនសន្តិភាពកើតចំពោះរូបគាត់)។
3. ទេវតាឈ្មោះ មីកាអ៊ីល ជាអ្នកនាំទឹកភ្លៀង។
4. ទេវតាឈ្មោះ ម៉ាលីគុលម៉ោត(ទេវតាដកយកជីវិត ឬយមរាជ) ជាអ្នកគ្រប់គ្រងខាងការដកយកព្រលឹងមនុស្សនៅពេលពួកគេស្លាប់។
5. ទេវតាទាំងនោះជាខ្ញុំបម្រើរបស់អល់ឡោះ។
6. ហេតុដូច្នេះ ពួកយើងចាំបាច់គោរពពួកគេ តម្កើងពួកគេ។
7. ក៏ប៉ុន្តែយើងមិនសំពះបូជាពួកគេ មិនបួងសួងសុំអ្វីពីពួកគេ ហើយមិនចាត់ទុកពួកគេជាកូនប្រុស ឬកូនស្រីរបស់អល់ឡោះនោះឡើយ។
8. ពោលគឺយើងត្រូវគោរពសក្ការៈចំពោះអល់ឡោះតែមួយគត់ជាអ្នកដែលបានបង្កើតពួកគេ។
9. អល់ឡោះបានមានព្រះបន្ទូលថា៖

﴿ وَقَالُواْ ٱتَّخَذَ ٱلرَّحۡمَٰنُ وَلَدٗاۗ سُبۡحَٰنَهُۥۚ بَلۡ عِبَادٞ مُّكۡرَمُونَ ٢٦ لَا يَسۡبِقُونَهُۥ بِٱلۡقَوۡلِ وَهُم بِأَمۡرِهِۦ يَعۡمَلُونَ ٢٧ يَعۡلَمُ مَا بَيۡنَ أَيۡدِيهِمۡ وَمَا خَلۡفَهُمۡ وَلَا يَشۡفَعُونَ إِلَّا لِمَنِ ٱرۡتَضَىٰ وَهُم مِّنۡ خَشۡيَتِهِۦ مُشۡفِقُونَ ٢٨ ۞ وَمَن يَقُلۡ مِنۡهُمۡ إِنِّيٓ إِلَٰهٞ مِّن دُونِهِۦ فَذَٰلِكَ نَجۡزِيهِ جَهَنَّمَۚ كَذَٰلِكَ نَجۡزِي ٱلظَّٰلِمِينَ ٢٩ ﴾ الأنبياء: ٢٦ - ٢٩

មានន័យថា៖«ពួកអ្នកគោរពពហុទេពនិយាយថា ព្រះជាម្ចាស់ទ្រង់មានកូន ទ្រង់មហាស្អាតស្អំ ប៉ុន្តែពួកទេវតាទាំងនោះជាខ្ញុំបម្រើដ៏ថ្លៃថ្លា។ ពួកគេមិននិយាយអ្វីមួយលើកលែងតែទ្រង់ប្រើឱ្យនិយាយ ហើយពួកគេអនុវត្តតាមការបង្គាប់បញ្ជារបស់ទ្រង់។ ទ្រង់ដឹងពីអ្វីដែលនៅពីមុខនិងនៅពីក្រោយពួកគេ ពួកគេមិនអាចសង្គ្រោះនរណាម្នាក់លើកលែងតែចំពោះអ្នកដែលទ្រង់អនុញ្ញាត ហើយពួកគេភ័យខ្លាចតែធ្វើខុសនឹងបទបញ្ជារបស់ទ្រង់។ ចំពោះទេវតាណាដែលអះអាងថាខ្លួនគេជាព្រះផ្សេងពីអល់ឡោះនោះ យើងនឹងដាក់គេចូលទៅក្នុងភ្លើងនរក ក៏ដូចគ្នានេះដែរយើងតបស្នងចំពោះពួកអ្នកដែលអគតិគោរពពហុទេពនិយម»។

# ជំពូកទី ៨
# ជំនឿចំពោះគម្ពីរៗដែលគេបញ្ចុះពីលើមេឃ

1. យើងជឿថាអល់ឡោះបានបញ្ចុះគម្ពីរៗទៅចំពោះអ្នកនាំសារខ្លះរបស់ទ្រង់ ដើម្បីឱ្យពួកគេផ្តល់គម្ពីរទាំងនោះដល់មនុស្សទាំងឡាយ។
2. គម្ពីរទាំងនេះជាព្រះបន្ទូលរបស់អល់ឡោះ។
3. ក្នុងនោះមាន គម្ពីរស៊ូហ៊ុហ្វរបស់ណាពីអ៊ីព្រហ៊ីម។
   គម្ពីរ អាត់តាវ៉ូរ៉ត ដែលគេបញ្ចុះឱ្យព្យាការី មូសា( ម៉ូស៊ីស )
   គម្ពីរ អាសហ្សាប៊ូរ ដែលគេបញ្ចុះឱ្យព្យាការី ដាវូត( ដាវីត )
   គម្ពីរ អាល់អ៊ីនជីល ដែលគេបញ្ចុះឱ្យព្យាការី អ៊ីសា( យេស៊ូ )
   គម្ពីរ អាល់គួរអាន ដែលគេបញ្ចុះឱ្យព្យាការី មូហាំម៉ាត់( សូមសុខសន្តិភាពកើតមានចំពោះពួកគាត់ )។
4. ពិតប្រាកដណាស់ ពួកជ្វីហ្វ( យ៉ាហ៊ូដ )និងពួកគ្រិស្ទាន( ណាសរ៉ានី ) ពួកគេបានកែប្រែខ្លះនូវអ្វីដែលមាននៅក្នុងគម្ពីរតាវ៉ូរ៉ត និងគម្ពីរអាល់-អ៊ីនជីល។
5. រាល់អ្វីៗដែលមានក្នុងគម្ពីរដែលគេបានបញ្ចុះមុនៗនោះ ត្រូវចាត់ទុកជាអសារបង់ដោយយើងមានគម្ពីរអាល់គួរអាន ហើយរាល់សាសនាដែលផ្សេងពីសាសនាអ៊ីស្លាមត្រូវក្លាយជាអសារបង់។
6. រាល់អ្វីដែលអ្នកឃើញនៅក្នុងគម្ពីរៗដែលគេបានបញ្ចុះពីលើមេឃមកផ្ទុយនឹងអ្វីដែលមានក្នុងគម្ពីរអាល់គួរអាន គឺគម្ពីរនោះអាចត្រូវបានគេកែប្រែ ឬត្រូវចាត់ទុកជាមោឃៈ។
7. អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿ وَأَنزَلْنَآ إِلَيْكَ ٱلْكِتَٰبَ بِٱلْحَقِّ مُصَدِّقًا لِّمَا بَيْنَ يَدَيْهِ مِنَ ٱلْكِتَٰبِ وَمُهَيْمِنًا عَلَيْهِ ﴾ المائدة: ٤٨

មានន័យថាៈ «យើងបានបញ្ចុះទៅកាន់អ្នកនូវគម្ពីរមួយប្រកបដោយភាពសច្ចៈ ដើម្បីបញ្ជាក់ពីគម្ពីរមុនៗ និងបកស្រាយបំភ្លឺពីការកែប្រែរបស់គម្ពីរមុនៗ»។

8. ពិតប្រាកដណាស់អល់ឡោះបានបញ្ចុះគម្ពីរអាល់គួរអានជាភាសារអារ៉ាប់។ អល់ឡោះបានជានារក្សាគម្ពីរនេះពីការកែប្រែទាំងឡាយ។ ដូចអល់ឡោះបានមានព្រះបន្ទូលថាៈ

﴿ إِنَّا نَحْنُ نَزَّلْنَا ٱلذِّكْرَ وَإِنَّا لَهُۥ لَحَٰفِظُونَ ﴿٩﴾ ﴾ الحجر: ٩

មានន័យថាៈ ‹‹ពិតប្រាកដណាស់យើង(អល់ឡោះ)បានបញ្ចុះគម្ពីរអាល់គួរអាន ហើយពិតប្រាកដណាស់យើងជាអ្នកថែរក្សាវាជាដរាបរៀងទៅ››។

# ជំពូកទី៩
# ជំនឿចំពោះពួកព្យាការី

1. យើងជឿថាអល់ឡោះបានជ្រើសរើសក្នុងចំណោមមនុស្សនូវពួកព្យាការី ហើយមានតែពួកគេប៉ុណ្ណោះដែលអល់ឡោះប្រាប់អំពីដំណឹងលើមេឃ។
2. អល់ឡោះបានជ្រើសរើសក្នុងចំណោមពួកព្យាការីទាំងនោះនូវអ្នកនាំសាររបស់ទ្រង់។
3. ទ្រង់បានផ្តល់(វ៉ាហ៊ី)ព្រះបន្ទូលស្តីពីក្បួនវិន័យទាំងឡាយដល់ពួកគេដើម្បីផ្សព្វផ្សាយដល់មនុស្ស និងបង្រៀនក្បួនវិន័យទាំងឡាយដល់មនុស្សទូទៅ ។
4. ក្នុងចំណោមពួកព្យាការីទាំងនោះ មានពួកព្យាការីដែលគេឱ្យឈ្មោះថា"កំពូលអ្នកផ្តេផ្តាចិត្ត"ពួកគេទាំងនោះគឺជាអ្នកទទួលបន្ទុកដ៏ធ្ងន់ធ្ងនរបំផុតក្នុងការអំពាវនាវមនុស្សទៅរកអល់ឡោះ។ ពួកគេទាំងនោះមាន ព្យាការី ណួហ ព្យាការីអ៊ីព្រហ៊ីម មូសា(ម៉ូស៊ីស) អ៊ីសា(យេស៊ូ) ហើយនិងមូហាំម៉ាត់(សូមអល់ឡោះជូនពរជ័យចំពោះពួកគាត់)។
5. ចូរជ្រាបថា នៅពេលដែលអ្នកចូលអ៊ីស្លាម អ៊ីស្លាមមិនប្រើអ្នកឱ្យប្រឆាំងចំពោះមូសា(ម៉ូស៊ីស) ឬអ៊ីសា(យេស៊ូ) ហើយនិងបណ្តាព្យាការីដទៃទៀតនោះទេ។
6. ក៏ប៉ុន្តែអ៊ីស្លាមបញ្ជាក់ប្រាប់អ្នកអំពីរបៀបលក្ខណៈដ៏ត្រឹមត្រូវនៃការជឿគោរពចំពោះពួកគេ។
7. អល់ឡោះបានមានព្រះបន្ទូលថា៖

﴿ وَأَنزَلۡنَآ إِلَيۡكَ ٱلۡكِتَٰبَ بِٱلۡحَقِّ مُصَدِّقٗا لِّمَا بَيۡنَ يَدَيۡهِ مِنَ ٱلۡكِتَٰبِ وَمُهَيۡمِنًا عَلَيۡهِۖ ﴾ المائدة: ٤٨

មានន័យថា៖(យើងបានបញ្ចុះទៅកាន់អ្នកនូវគម្ពីរដោយសច្ចៈដើម្បីបញ្ជាក់ពីគម្ពីរមុនៗ និងបកស្រាយបំភ្លឺពីការកែប្រែរបស់គម្ពីរមុនៗ)។ មានន័យថា បញ្ជាក់ពីភាពពិតដែលគេបានកែប្រែ។ ប្រាកដណាស់អល់ឡោះបានមានព្រះបន្ទូលប្រាប់ពីឈ្មោះព្យាការីជាច្រើននៅក្នុងគម្ពីរអាល់គួរអាន អល់ឡោះបានមានព្រះបន្ទូលថា៖

﴿ قُولُوٓاْ ءَامَنَّا بِٱللَّهِ وَمَآ أُنزِلَ إِلَيۡنَا وَمَآ أُنزِلَ إِلَىٰٓ إِبۡرَٰهِـۧمَ وَإِسۡمَٰعِيلَ وَإِسۡحَٰقَ وَيَعۡقُوبَ وَٱلۡأَسۡبَاطِ وَمَآ أُوتِيَ مُوسَىٰ وَعِيسَىٰ وَمَآ أُوتِيَ ٱلنَّبِيُّونَ مِن رَّبِّهِمۡ لَا نُفَرِّقُ بَيۡنَ أَحَدٖ مِّنۡهُمۡ وَنَحۡنُ لَهُۥ مُسۡلِمُونَ ١٣٦ ﴾
البقرة: ١٣٦

មានន័យថា៖(ចូរពួកអ្នកថាចុះ ពួកយើងមានជំនឿចំពោះអល់ឡោះ ហើយនិងអ្វីៗដែលអល់ឡោះបានបញ្ចុះមកចំពោះយើង និងចំពោះអ៊ីព្រហ៊ីម អ៊ីស្មាអែល អ៊ីស្ហាក យ៉ាក់កូប និងកូនចៅពួកគេ ហើយនិងមូសា(ម៉ូស៊ីស) អ៊ីសា(យេស៊ូ) ហើយនិងអ្វីៗដែលអល់ឡោះបានប្រទានចុះមកចំពោះពួកព្យាការីដទៃទៀត ដោយពួកយើងមិនបានបែងចែកអ្នកណាម្នាក់ក្នុងចំណោមពួកគេឡើយ ហើយពួកយើងប្រគល់ខ្លួនជូនចូលចំពោះទ្រង់)។

8. ព្យាការីអាដាំ គឺជាព្យាការីដំបូងគេបង្អស់ក្នុងចំណោមព្យាការីទាំងឡាយ
9. ព្យាការីចុងក្រោយបង្អស់គឺព្យាការីមូហាំម៉ាត់ (សូមសន្តិភាពកើតមានចំពោះគាត់) គ្មានព្យាការីណាមក បន្ទាប់ពីគាត់ឡើយ។

10. ហេតុដូច្នេះ សាសនារបស់គាត់ គឺជាសាសនាពិតតែមួយគត់ ដែលនៅស្ថិតស្ថេររហូតដល់ថ្ងៃបរលោក
11. គាត់គឺ មូហាំម៉ាត់ កូន អាប់ឌុលឡោះ កូនអាប់ឌុលមូតាឡឹប កូនហាស៊ីម ជនជាតិអារ៉ាប់មកពីកុលសម្ព័ន្ធគូរ៉េស្សដ៏ល្បីល្បែង មកពីពូជពង្សព្យាការីអ៊ីព្រហ៊ីម និងអ៊ីស្មាអែល( សូមសុខសន្តិភាពកើតមានចំពោះពួកគេទាំងពីរ )។
12. គាត់បានកើតនៅទីក្រុងម៉ឹក្កះ(អារ៉ាប៊ីសេអូឌីត) ឆ្នាំដំរី(៥៧១គ.ស)។
13. អល់ឡោះបានប្រទានការត្រាស់បន្ទូល(វ៉ាហ៊ី)ដល់គាត់ជាព្យាការី នៅពេលដែលគាត់មានអាយុ៤០ឆ្នាំ។
14. ក្រោយពេលក្លាយជាព្យាការីគាត់ធ្វើការអំពាវនាវមនុស្សឱ្យចូលអ៊ីស្លាម នៅទីក្រុងម៉ឹក្កះអស់រយៈពេល១៣ឆ្នាំ។
15. មានអ្នកស្រុកម៉ឹក្កះតិចតួចណាស់ដែលជឿតាមគាត់។
16. ដូច្នេះគាត់ក៏បានភៀសខ្លួនទៅកាន់ទីក្រុងម៉ាឌីណះ នៅទីនោះគាត់ក៏បានអំពាវនាវមនុស្សឱ្យចូលអ៊ីស្លាម ហើយអ្នកទាំងនោះក៏មានជំនឿចំពោះគាត់។
17. គាត់បានរំដោះទីក្រុងម៉ឹក្កះមកវិញ (ដែលជាទីកន្លែងកំណើតរបស់គាត់)នៅឆ្នាំទី៨ហ.ស (ឆ្នាំភៀសខ្លួនទៅម៉ាឌីណះ)។
18. គាត់បានទទួលមរណភាពនៅពេលដែលគាត់មានអាយុ៦៣ឆ្នាំ។ គាត់បានទទួលមរណភាពបន្ទាប់ពីការបញ្ចុះគម្ពីរអាល់គួរអានពីអល់ឡោះជាម្ចាស់មកដល់គាត់បានចប់សព្វគ្រប់ ហើយពួកអារ៉ាប់ទាំងអស់ក៏បានចូលអ៊ីស្លាមរួចរាល់ហើយដែរ។

# ជំពូកទី១០
# ជំនឿចំពោះថ្ងៃបរលោក

1. យើងជឿថា ក្រោយពីការរស់នៅលើលោកីយ៍នេះ គឺមានការរស់នៅផ្សេងទៀត។
2. នៅពេលដែលអាយុកាលពិភពលោកបានដល់កំណត់ ពិតប្រាកដណាស់អល់ឡោះនឹងប្រើទេវតាឱ្យផ្លុំត្រែ រំពេចនោះមនុស្សទាំងអស់ត្រូវស្លាប់។
3. ក្រោយមកទេវតាក៏បានផ្លុំត្រែនោះម្ដងទៀត ដូច្នេះមនុស្សទាំងអស់ តាំងពីសម័យព្យាការីអាដាំ រហូតដល់ សម័យព្យាការីមូហាំម៉ាត់ នឹងងើបចេញពីផ្នូរទាំងអស់ដោយឆ្ពោះទៅកាន់កន្លែងជំនុំជម្រះ។
4. ក្រោយមកអល់ឡោះនឹងជំនុំជំរះពួកគេតាមទង្វើរបស់ពួកគេនៅលើលោកីយ៍នេះ។
5. រីឯអ្នកដែលមានជំនឿចំពោះអល់ឡោះ ចំពោះអ្នកនាំសារអល់ឡោះ ហើយពួកគេបានធ្វើអំពើល្អ ដូច្នេះ អល់ឡោះនឹងឱ្យពួកគេចូលឋាន-សួគ៍របស់ទ្រង់។
6. នៅក្នុងឋានសួគ៌ពួកគេសប្បាយរីករាយជាមួយនឹងក្ដីប្រទានរបស់អល់ឡោះគ្មានទីបញ្ចប់។
7. រីឯអ្នកដែលប្រឆាំងនឹងអ្នកនាំសាររបស់អល់ឡោះ ប្រឆាំងនឹងបញ្ជារបស់អល់ឡោះ ពួកគេនឹងចុះនរក។
8. នៅក្នុងនរកត្រូវគេធ្វើទារុណកម្មសែនឈឺចាប់ខ្លោចផ្សាជាទីបំផុតដោយគ្មានថ្ងៃបញ្ចប់។

9. បពិត្រអល់ឡោះជាម្ចាស់ សូមទ្រង់មេត្តាប្រទានឋានសួគ៌ដល់ពួកយើងផងចុះ សូមទ្រង់បញ្ចៀសពួកយើង ពីភ្លើងនរក។ ( សូមទ្រង់ទទួលយកការបួងសួងនេះផងចុះ )។

10. អល់ឡោះទ្រង់បានមានបន្ទូលថា៖

﴿ فَأَمَّا مَن طَغَىٰ ﴿٣٧﴾ وَءَاثَرَ ٱلْحَيَوٰةَ ٱلدُّنْيَا ﴿٣٨﴾ فَإِنَّ ٱلْجَحِيمَ هِىَ ٱلْمَأْوَىٰ ﴿٣٩﴾ وَأَمَّا مَنْ خَافَ مَقَامَ رَبِّهِۦ وَنَهَى ٱلنَّفْسَ عَنِ ٱلْهَوَىٰ ﴿٤٠﴾ فَإِنَّ ٱلْجَنَّةَ هِىَ ٱلْمَأْوَىٰ ﴿٤١﴾ ﴾ النازعات: ٣٧ - ٤١

មានន័យថា៖ «រីឯអ្នកដែលបានបំពាន ហើយឱ្យតំលៃជីវិតលើលោកីយ៍ជាងថ្ងៃបរលោក ពិតប្រាកដណាស់ភ្លើងនរកគឺជាកន្លែងជ្រកកោនរបស់គេ។ ឯចំណែកអ្នកដែលកោតខ្លាច ពេលដែលគេឈរជំនុំជម្រះនៅចំពោះមុខព្រះជាម្ចាស់របស់គេ ហើយបានរក្សាការពារខ្លួនពីកិលេសតណ្ហា ពិតប្រាកដណាស់ឋានសួគ៌គឺជាទីជ្រកកោនសម្រាប់គេ»។

# ជំពូកទី ១១

# ការគោរពសក្ការៈ
# (កិច្ចប្រតិបត្តិនៃសាសនា)

1. កិច្ចប្រតិបត្តិក្នុងសាសនាអ៊ីស្លាមបែងចែកជាពីរប្រភេទធំៗគឺ៖
   ក. ការគោរពសក្ការៈ៖ គឺជាអត្តសញ្ញាណ និងជាកាតព្វកិច្ចនៃការគោរពសក្ការៈ ដូចជាការថ្វាយបង្គំ បរិច្ចាគទ្រព្យ តមអាហារពេលថ្ងៃ(បួស) និងធ្វើធម្មយាត្រា (ដំណើរទៅទីក្រុងម៉ឺក្កះ)។
   ខ. ទំនាក់ទំនង៖ រាល់សកម្មភាពរស់នៅទាំងអស់ទាក់ទងនឹងបុគ្គល ឬគ្រួសារ ឬសង្គម ឬប្រជាជាតិអ៊ីស្លាមទាំងមូល...ទោះជាទាក់ទងនឹងបញ្ហានយោបាយ ឬសេដ្ឋកិច្ច ឬវប្បធម៌ ឬបញ្ហាតុលាការ ឬសីលធម៌...ក្នុងតំបន់ ឬអន្តរជាតិ។
2. ការទំនាក់ទំនង៖
   នៅពេលដែលការទំនាក់ទំនងអនុវត្តតាមច្បាប់សារីអាត់របស់អល់ឡោះនោះ នឹងក្លាយទៅជាការគោរពសក្ការៈក្នុងន័យទូទៅ។
3. ក្នុងកូនសៀវភៅដ៏តូចនេះមិនបានបញ្ជាក់អំពីរបៀបនៃទំនាក់ទំនងនោះទេ។ អ្នកចាំបាច់ត្រូវស្វែងរកមើលក្នុងសៀវភៅក្បួនច្បាប់អ៊ីស្លាមផ្សេងៗ ឬអ្នកអាចសួរបុគ្គលណាក៏បាន ដែលជាអ្នកចេះដឹងជ្រៅជ្រះ ឬក៏អង្គការអ៊ីស្លាមនានា។
4. គោលគ្រឹះអ៊ីស្លាមផ្នែកប្រតិបត្តិមាន៥ ប្រការគឺ ពាក្យសច្ចាទាំងពីរ ការថ្វាយបង្គំ បរិច្ចាគទ្រព្យ តមអាហារ ធ្វើយម្មយាត្រា។

# ជំពូកទី ១២
# ពាក្យសច្ចាទាំងពីរ

1. អ្នកត្រូវសច្ចានឹងសម្តីរបស់អ្នក ហើយជឿក្នុងចិត្តរបស់អ្នក ដោយពោលថា៖
2. (أشهد أن لا إله إلا الله) មានន័យថា៖ (ខ្ញុំសច្ចាថា ពិតប្រាកដណាស់គ្មានទេម្ចាស់ក្រៅពីអល់ឡោះ)[1]
3. (وأشهد أن محمدا رسول الله) មានន័យថា ៖ (ហើយខ្ញុំសច្ចាទៀតថា មូហាំម៉ាត់ជាអ្នកនាំសារអល់ឡោះ)[2]

[1] .អត្ថន័យនៃពាក្យសច្ចានេះ គឺផ្តេជ្ញាទទួលស្គាល់ និងជឿជាក់ក្នុងចិត្តចំពោះភាពជាព្រះជាម្ចាស់តែមួយរបស់អល់ឡោះ គ្មានអ្នកផ្សេងក្រៅពីទ្រង់ មានតែអល់ឡោះដែលសាកសមចំពោះការគោរពសក្ការៈនេះ។

[2] .អត្ថន័យនៃពាក្យសច្ចាទីពីរ គឺផ្តេជ្ញាចិត្តទទួលស្គាល់ និងជឿជាក់ក្នុងចិត្តថាពព្យាការីមូហាំម៉ាត់ជាអ្នកនាំសាររបស់អល់ឡោះ នាំគម្ពីរអាល់គួរអានមកឱ្យយើង ដែលក្នុងគម្ពីរនិងធម្មនិយម(ស៊ុណ្ណះ) ជាមាគ៌ាដ៏សុក្រឹតសម្រាប់ជីវិត។

# ជំពូកទី១៣
# ការថ្វាយបង្គំ

1. យើងថ្វាយបង្គំរៀងរាល់ថ្ងៃ ហើយក្នុងមួយថ្ងៃ៥ដង។
2. ថ្វាយបង្គំពេលអរុណោរះ (សាឡាតស៊ូហ្គោះ) ពីរដងឱន។ ពេលវេលាបន្ទាប់ពីអារុណោរះរហូតដល់ ព្រះអាទិត្យរះ ។
3. ថ្វាយបង្គំពេលថ្ងៃរសៀល(សាឡាតហ្សូហ្ស) ៤ដងឱន។ ពេលវេលា
4. ចាប់ពីព្រះអាទិត្យជ្រេទៅទិសខាងលិចបន្តិចរហូតដល់ពាក់កណ្តាល ចន្លោះថ្ងៃជ្រេនិងថ្ងៃលិច។
5. ថ្វាយបង្គំពេលថ្ងៃបាក់រសៀល(សាឡាតអាសើរ) ៤ដងឱន។ ពេលវេលារបស់វាគឺចាប់ពីម៉ោងអស់ពេលថ្វាយបង្គំថ្ងៃរសៀល រហូតដល់ថ្ងៃលិច។
6. ថ្វាយបង្គំក្រោយថ្ងៃលិចបន្តិច(សាឡាតម៉ាហ្គ្រិប) ៣ដងឱន។ ពេលវេលាចាប់ពីថ្ងៃលិចរហូតដល់បាត់ជើងមេឃពណ៌ក្រហម (ក្រោយពេលថ្ងៃលិចប្រហែល១ម៉ោង១៥នាទី)។
7. ថ្វាយបង្គំពេលព្រលប់(សាឡាតអ៊ីសា) ៤ដងឱន។ ពេលវេលាដែលប្រសើរបំផុតចាប់ពីពេលផុតម៉ោងថ្វាយបង្គំម៉ាហ្គ្រិបរហូតដល់ពាក់កណ្តាលអាធ្រាត។ អាចពន្យារដល់ពេលអារុណោរះ។

# ជំពូកទី ១៤
# ការជម្រះសម្អាត

1. ចាំបាច់ចំពោះអ្នកមូស្លីមត្រូវតែជម្រះសម្អាតនៅពេលថ្វាយបង្គំ។
2. ការជម្រះសម្អាតមានពីរប្រភេទ៖
ការយកទឹកវូហ្ទុ( ការជម្រះសម្អាតតូច ) និងការងូតទឹក( ការជម្រះសម្អាតធំ )។

## ក.ការយកទឹកវូហ្ទុ(ជម្រះសម្អាតតូច)យើងត្រូវធ្វើដូចខាងក្រោម៖

3. នឹកក្នុងចិត្តថា នេះជាការយកទឹកវូហ្ទុដើម្បីថ្វាយបង្គំ
4. សូត្រថា( بسم الله الرحمن الرحيم )
5. លាងដៃទាំងពីរដោយទឹកស្អាតរហូតដល់កដៃទាំងពីរ ខ្ពុរមាត់ រឺតទឹកចូលក្នុងច្រមុះ ហើយញើសចេញមកវិញដើម្បីសំអាតរន្ធច្រមុះ។
6. លុបមុខនឹងទឹក។
7. លាងដៃទាំងពីររហូតដល់កែងដៃដោយចាប់ពីដៃស្តាំមុន។
8. យកដៃផ្សើមទឹក រួចជូតក្បាលនិងត្រចៀកទាំងពីរ។
9. លាងជើងទាំងពីររហូតដល់ភ្នែកគោលដោយចាប់ផ្តើមពីជើងស្តាំមុន។
10. បន្ទាប់ពីចប់សព្វគ្រប់ យើងពោលពាក្យសច្ចាទាំងពីរ
11. នៅពេលដែលយើងយកទឹកវូហ្ទុរួច(ជម្រះកាយដើម្បីថ្វាយបង្គំ) យើងមិនចាំបាច់យកម្តងទៀតនោះទេលើកលែងតែមានប្រការណាមួយដែលធ្វើឱ្យវាខូច។
12. ប្រការដែលធ្វើឱ្យខូចទឹកវូហ្ទុមាន ការបត់ជើងតូច ការបត់ជើងធំ ផោម ដេកលក់។

## ខ. ការងូតទឹក( ការជម្រះសម្អាតធំ )

13. អ្នកមូស្លីមចាំបាច់ត្រូវតែងូតទឹកក្នុងករណីដូចខាងក្រោម៖

១. ចេញទឹកកាមដោយធម្មជាតិ

២. រួមដំណេក ទោះបានសម្រេច ឬមិនបានសម្រេច

៣. នៅពេលស្រ្តីអស់រដូវ

៤.នៅពេលស្រ្តីអស់ឈាមសម្រាលកូន

14. ត្រូវងូតទឹកស្អាតហើយងូតអោយសព្វខ្លួនប្រាណទាំងមូល។

## គ. អាត់តាយ៉ាំមុំ( ការជម្រះសម្អាតស្ងួត )

15. យើងធ្វើតាយ៉ាំមុំនេះនៅពេលដែលយើងគ្មានទឹកសម្រាប់ជម្រះកាយដើម្បីថ្វាយបង្គំ ឬសម្រាប់ងូត ឬនៅពេលយើងឈឺ ឬមូលហេតុផ្សេងៗទៀតដែលធ្វើឱ្យយើងមិនអាចប៉ះទឹកបាន។

16. យើងធ្វើតាយ៉ាំមុំនេះដោយគ្រាន់តែយកបាតដៃទាំងពីរទៅទះលើដីដែលជ្រះស្អាត។ ក្រោយមកយកបាតដៃទាំងពីរជូតលើមុខ (ជូតតែម្ដង)។ បន្ទាប់ពីជូតមុខរួចជូតដៃទាំងពីរត្រឹមកដៃប៉ុណ្ណោះ។

# ជំពូកទី ១៥
# តើយើងថ្វាយបង្គំយ៉ាងដូចម្ដេច?

1. ជាការល្អបំផុតដែលអ្នកចូលរួមថ្វាយបង្គំជាមួយនឹងពួកអ្នកមូស្លីមដទៃទៀតនៅម៉ាស្ជិទ(វិហារ) អ្នកនឹងទទួលបានផលបុណ្យជាច្រើនពីអល់ឡោះ ហើយអ្នកនឹងបានហាត់រៀនយ៉ាងងាយស្រួលពីរបៀបរបបថ្វាយបង្គំដ៏ត្រឹមត្រូវ។
2. ក្នុងករណីដែលអ្នកថ្វាយបង្គំម្នាក់ឯង អ្នកត្រូវអនុវត្តដូចខាងក្រោម៖
3. ត្រូវដឹងច្បាស់ថា សំលៀកបំពាក់របស់អ្នក ខ្លួនប្រាណរបស់អ្នក និងទីកន្លែងថ្វាយបង្គំរបស់អ្នកស្អាត។
4. បែរទៅទិសគិបឡាត(ទិសខាងលិច)។
5. លើកដៃទាំងពីរត្រឹមស្មា ឬត្រឹមត្រចៀក ហើយត្រូវសូត្រថា(الله أكبر)
6. ដាក់ដៃទាំងពីរលើទ្រូង ដៃស្ដាំលើដៃឆ្វេង
7. សូត្រជំពូកអាល់ហ្វាទីហះ(سورة الفاتحة)
8. ឱនទៅមុខដៃប្រត់ជង្គង់ ហើយសូត្រថា(الله أكبر) ខ្នងដាក់ឱ្យត្រង់ជាមួយនឹងក្បាលរបស់អ្នក ហើយសម្លឹងភ្នែកទៅក្រោម។
9. នៅពេលឱនសូត្រថា(سبحان ربي العظيم) បីដង។
10. ងើបមកវិញដោយសូត្រថា(سمع الله لمن حمده ، ربنا ولك الحمد) ។
11. យើងត្រូវសូត្រថា(الله أكبر) ហើយឱនក្រាបដោយដាក់ថ្ងាស ច្រមុះ បាតដៃទាំងពីរ ក្បាលជង្គង់ទាំងពីរ ម្រាមជើងទាំងអស់ដល់ដី ឬកម្រាល រួចត្រូវសូត្រថា(سبحان ربي الأعلى)បីដង។
12. ត្រូវងើបអង្គុយដោយសូត្រថា (الله أكبر) ហើយនៅពេលអង្គុយនោះ

ត្រូវសូត្រថា( رب اغفرلي وارحمني )។

13. ត្រូវសូត្រថា ( الله أكبر ) ហើយឱនក្រាបលើកទីពីរដោយធ្វើដូចលើកទីមួយ រួចត្រូវសូត្រថា( سبحان ربي الأعلى )បីដង។

14. ក្រោយពីបានបញ្ចប់ការក្រាបលើកទីពីរនេះរួចរាល់គឺយើងបានបញ្ចប់មួយដងឱននៃការថ្វាយបង្គំ។

15. ក្រោយពីនោះសូត្រទៀតថា( الله أكبر ) រួចថ្វាយបង្គំឱនទីពីរបន្តទៀតដោយអនុវត្តដូចឱនទីមួយដែរ។

16. ក្រោយពីបានបញ្ចប់ឱនទីពីរនេះ យើងអង្គុយសូត្រអាត់តាស្ហះហ៊ុដ ( التشهد ) ហើយនិងសាឡាវ៉ាតចំពោះព្យាការី( والصلاة الإبراهيمية )[3] ។

17. ត្រូវងាកស្តាំដោយសូត្រថា( السلام عليكم ورحمة الله )

18. រួចងាកឆ្វេងសូត្រថា( السلام عليكم ورحمة الله )

19. នេះជាការថ្វាយបង្គំពេលស៊ូហ្ពោះ( الصبح ) ព្រោះវាមានតែពីរដងឱនប៉ុណ្ណោះ។

20. រីឯការថ្វាយបង្គំនៅពេលហ្សូហ្ស( الظهر ) យើងត្រូវក្រោកឈរក្រោយពីអង្គុយអាត់តាស្ហះហ៊ុដ( التشهد )ដោយយើងមិនបាច់សូត្រការសាឡាវ៉ាត( والصلاة الإبراهيمية ) នៅក្នុងអាត់តាស្ហះហ៊ុដ( التشهد )នោះទេ ពីព្រោះយើងត្រូវបន្តការថ្វាយបង្គំនេះពីរដងឱនទៀត។

21. នៅចុងបញ្ចប់ការឱនទីពីរនេះ ត្រូវអង្គុយអាត់តាស្ហះហ៊ុដទៀតដែលក្នុងនោះយើងត្រូវសាឡាវ៉ាត( والصلاة الإبراهيمية ) ក្រោយមកត្រូវងាក

[3] ចូរស្វែងរកមើលគំរូអាត់តាស្ហះហ៊ុដ(التشهد) ហើយនិងសាឡាវ៉ាត (والصلاة الإبراهيمية) នៅទំព័រចុងក្រោយនៃសៀវភៅនេះ (មើលក្នុងសេចក្តីបន្ថែមទី ២)

ស្តាំធ្វេងដោយសូត្រ( السلام عليكم ورحمة الله )
22. ក៏ដូចគ្នានេះដែរការថ្វាយបង្គំពេលអាសើរ និងអុីសា។
23. តែថ្វាយបង្គំពេលម៉ាហ្រ៊ិបមានតែបីដងឱនតែប៉ុណ្ណោះ ដូច្នេះយើងថ្វាយបង្គំបន្ទាប់ពីអង្គុយអាត់តាស្ហះហ៊ុដ( التشهد ) រួចតែមួយដងឱនទៀតប៉ុណ្ណោះ។

## ហេតុអ្វីយើងត្រូវថ្វាយបង្គំ?

24. អ្នកមូស្លីមថ្វាយបង្គំជាការគោរពសក្ការៈចំពោះអល់ឡោះ។ ការថ្វាយបង្គំគឺជាការប្រតិបត្តិដ៏សំខាន់បំផុតដែលអល់ឡោះជាម្ចាស់ទ្រង់សព្វព្រះទ័យចង់ឱ្យមនុស្សគោរពប្រតិបត្តិ។
25. ជាការដឹងគុណចំពោះអល់ឡោះដ៏មហាខ្ពង់ខ្ពស់ដែលទ្រង់បានបង្កើតយើងឱ្យមានរូបសម្បត្តិដ៏ល្អប្រសើរជាទីបំផុត។
26. ទ្រង់បានប្រទានដល់យើងនូវសាសនាអុីស្លាម។
27. ដើម្បីផ្សារភ្ជាប់អ្នកមូស្លីមជាមួយនឹងម្ចាស់របស់ពួកគេនៅក្នុងការថ្វាយបង្គំ ដោយសូត្រព្រះបន្ទូលអល់ឡោះ គឺគម្ពីរអាល់គួរអាន។
28. ដើម្បីឱ្យអ្នកមូស្លីមរំលឹកចំពោះម្ចាស់របស់ពួកគេ ហើយមិនភ្លេចទ្រង់ មិនភ្លេចរាល់បទបញ្ជារបស់ព្រះជាម្ចាស់ជាមួយនឹងភាពមមាញឹកនៃជីវិត។
29. ដើម្បីឱ្យអ្នកមូស្លីមបួងសួងចំពោះព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ សុំជំនួយក្តីសម្រេចជោគជ័យ និងក្តីចង្អុលបង្ហាញផ្លូវជាប្រចាំក្នុងភាពងងឹតអន្ធការនៃជីវិត។
30. ដើម្បីពង្រឹងក្តីស្រលាញ់ចំពោះអល់ឡោះនិងភាពកោតខ្លាចចំពោះទ្រង់

នៅក្នុងចិត្តរបស់អ្នកដែលថ្វាយបង្គំ។ ដូច្នេះអត្តចរិតរបស់គេនៅតែឋិតក្នុងភាពខ្ជាប់ខ្ជួនរតាមសាសនានិងក្បួនច្បាប់អ៊ីស្លាម។

31. ថ្វាយបង្គំដើម្បីទទួលបានផលបុណ្យ ហើយអល់ឡោះទ្រង់លុបលាងកំហុសនិងអំពើបាបរបស់យើង។

32. ដើម្បីជួបព្រះម្ចាស់នៅថ្ងៃបរលោក ហើយសប្បាយរីករាយជាមួយនឹងអ្វីដែលអល់ឡោះបានរៀបចំសម្រាប់គេនៅក្នុងឋានសួគ៌ដ៏មានបរមសុខ។

33. ការថ្វាយបង្គំគឺជាកម្មវិធីហ្វឹកហាត់និងអប់រំខ្លួន។ ប្រសិនបើគេប្រតិបត្តិបានល្អនឹងទទួលបានផលប្រយោជន៍ច្រើនសម្រាប់អ្នកមូស្លីម ទាំងផ្លូវកាយ អត្តចរិក និងចិត្តវិញ្ញាណ ឧទាហរណ៍៖ ការអនាម័យ សុខភាព សណ្តាប់ធ្នាប់ ភាពហ្មត់ចត់ ទៀងត្រង់ ភាតរភាព សមភាព និងសាមគ្គីភាពសង្គម ។ល។

# ជំពូកទី១៦

## ការបរិច្ចាគទ្រព្យ (الزكاة)

1. ពាក្យហ្សាកាត់ "الزكاة"នៅក្នុងន័យចំគឺភាពលូតលាស់ និងភាពជ្រះស្អាត។
2. ន័យបញ្ញត្តិក្នុងអ៊ីស្លាមមានន័យថា៖ ការបង់តាមភាគរយដែលគេកំណត់នៃទ្រព្យសម្បត្តិសន្សំទុករៀងរាល់ មួយខួបម្តងគិតតាមឆ្នាំចន្ទគតិ ចំណាយក្នុងផ្លូវល្អដែលគម្ពីរអាល់-គួរអានបានកំណត់។
3. នៅពេលទ្រព្យសម្បត្តិរបស់អ្នកគ្រប់ចំនួនដែលត្រូវបរិច្ចាគសម្រាប់មួយខួបម្តងគិតតាមឆ្នាំចន្ទគតិ។ គិតជាសាច់ប្រាក់មានតំលៃមិនតិចជាង ៨៥ក្រាមមាសសុទ្ធ(ប្រហែល១០០០ដុល្លា) ចាំបាច់អ្នកត្រូវបរិច្ចាគចំនួន១/២ (២.៥%)។
4. យកតំលៃដែលបានបរិច្ចាគនេះផ្តល់ជូនអ្នកក្រីក្រ អ្នកដំណើរដាច់សង្វែងតាមផ្លូវ ផ្គត់ផ្គង់ដល់ការអំពាវនាវអ៊ីស្លាម និងការតស៊ូក្នុងផ្លូវអល់ឡោះ ឬសម្រាប់ជាការលើកទឹកចិត្តចំពោះអ្នកដែលចង់ចូលអ៊ីស្លាម ឬជួយអ្នកដែលជំពាក់បំណុលគេច្រើន ហើយគ្មានលទ្ធភាពសងគេ។
5. ប្រសិនជាអ្នកមានទំនិញជួញដូរ ហើយគ្រប់ចំនួនដែលត្រូវបរិច្ចាគ គឺចាំបាច់អ្នកត្រូវតែបរិច្ចាគដែរ។
6. អ្នកអាចសាកសួរអ្នកដែលចេះដឹងបន្ថែមទៀត ឬអាចអានសៀវភៅៗដែលនិយាយអំពីបញ្ហានេះដើម្បីបង្កើនចំណេះដឹងរបស់អ្នកបន្ថែមទៀត។

## ហេតុអ្វីចាំបាច់ត្រូវបរិច្ចាគ?

1. យើងបរិច្ចាគដើម្បីជាការគោរពប្រតិបត្តិចំពោះអល់ឡោះ ពីព្រោះអល់ឡោះទ្រង់បានបង្គាប់ប្រើមកចំពោះយើង ហើយទ្រង់ស្រឡាញ់ពួកអ្នកដែលបរិច្ចាគទ្រព្យធ្វើទាន។
2. ដើម្បីគោរពអំណរគុណចំពោះអល់ឡោះដែលទ្រង់បានប្រទានទ្រព្យសម្បត្តិទាំងនេះដល់យើង និងបានធ្វើឱ្យយើងទទួលជោគជ័យក្នុងការប្រកបរបស់រកស៊ី។
3. ដើម្បីជួយដល់អ្នកក្រីក្រឱ្យពួកគាត់ទទួលបានសុភមង្គល និងជួយសង្គ្រោះដល់ពួកអ្នកដែលទទួលរងគ្រោះទុរភិក្ស។
4. ដើម្បីចូលរួមចំណែកក្នុងការលើកស្ទួយសង្គមអ៊ីស្លាម។
5. ដើម្បីចូលរួមចំណែកក្នុងការផ្សព្វផ្សាយសាសនាអ៊ីស្លាមនៅលើសកលលោក។
6. យើងបរិច្ចាគដើម្បីជម្រះខ្លួនយើងពីចិត្តរិះកំណាញ់។
7. ដើម្បីឱ្យខ្លួនឯងក្លាយជាម្ចាស់ទ្រព្យ ពុំមែនក្លាយជាទាសកររបស់ទ្រព្យនោះទេ។
8. បរិច្ចាគដើម្បីជម្រះសម្អាតទ្រព្យរបស់យើងពីភាពទុច្ចរិតដែលយើងបានប្រព្រឹត្តក្នុងពេលកំពុងរកស៊ី។
9. អល់ឡោះរក្សានិងផ្ដល់ពរជ័យដល់ទ្រព្យសម្បត្តិរបស់យើង។
10. បរិច្ចាគដើម្បីទទួលបានផលបុណ្យដ៏ល្អប្រសើរអំពីអល់ឡោះនៅថ្ងៃបរលោក។
11. ដើម្បីការពារកុំឱ្យពួកអ្នកទីទ័លក្រកើតចិត្តច្រណែនឈ្នានីស។

12. ដើម្បីការពារសង្គមរបស់យើងពីជម្លោះវណ្ណៈ ហើយចូលរួមចំណែកដោះស្រាយបញ្ហាសេដ្ឋកិច្ច។

13. អ្នកអាចបរិច្ចាគផងដែរដល់រតនាគាឥស្លាមដែលទទួលទ្រព្យបរិច្ចាគ ឬសមាគមអ៊ីស្លាមណាមួយមានការជឿទុកចិត្ត ដែលទទួលបន្ទុកក្នុងការប្រមូលនិងចែកចាយទ្រព្យបរិច្ចាគទាំងនេះ។

# ជំពូកទី១៧

## បួស(ការតមអាហារ)

1. នៅពេលខែរ៉ម៉ាហ្ទនមកដល់(ខែទី៩នៃឆ្នាំចន្ទគតិរបស់អ៊ីស្លាម)អ្នកមូស្លីមទាំងអស់ត្រូវតែតមអាហារក្នុងខែនេះជាការគោរពប្រតិបត្តិចំពោះអល់ឡោះនិងជាការដឹងគុណដល់ទ្រង់ដែលបានប្រទានព្រះគម្ពីរអាល់គួរអានចុះមកក្នុងខែនេះ។
2. ការតមនេះគឺតមការហូបចុក ផឹកទឹក រួមដំណេក ចាប់ពីពេលអរុណរះរហូតដល់ថ្ងៃលិច។
3. អ្នកណាដែលមានជំងឺឈឺថ្កាត់ក្នុងខែនេះ ឬត្រូវចេញដំណើរផ្លូវឆ្ងាយតាមច្បាប់អ៊ីស្លាមអនុគ្រោះចំពោះអ្នកទាំងនោះមិនបាច់បួសទេ។
4. បើសិនជាអ្នកជំងឺបានដាច់បួស ឬអ្នកដំណើរដែលបានដាច់បួស គេត្រូវបួសសងវិញនៅថ្ងៃផ្សេងតាមចំនួនថ្ងៃដែលរូបគេបានដាច់បួសនោះ។
5. នៅពេលចប់ខែរ៉ម៉ាហ្ទន ថ្ងៃបុណ្យស្រាយបួសនឹងមកដល់ គឺថ្ងៃទីមួយនៃខែស្ហាវ៉ាល ជាខែដែលនៅបន្ទាប់ពីខែរ៉ម៉ាហ្ទន។
6. នៅព្រឹកថ្ងៃបុណ្យនេះ អ្នកមូស្លីមទាំងអស់ត្រូវជួបជុំគ្នាដើម្បីធ្វើការថ្វាយបង្គំជួបជុំគ្នានៅទីវាលណាមួយ ឬនៅព្រះវិហារ ដើម្បីអរគុណចំពោះអល់ឡោះជាម្ចាស់ដែលទ្រង់មេត្តាប្រទានដល់ពួកគេបានបំពេញកាតព្វកិច្ចបួស។
7. អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលទាក់ទងនឹងកាតព្វកិច្ចដ៏សំខាន់នេះថា៖

﴿ يَٰٓأَيُّهَا ٱلَّذِينَ ءَامَنُواْ كُتِبَ عَلَيۡكُمُ ٱلصِّيَامُ كَمَا كُتِبَ عَلَى ٱلَّذِينَ مِن قَبۡلِكُمۡ لَعَلَّكُمۡ تَتَّقُونَ ١٨٣ ﴾ البقرة: ١٨٣

មានន័យថា៖ «ឱពួកអ្នកមានជំនឿ គេបានដាក់កាតព្វកិច្ចបួសលើពួកអ្នក ដូចដែលគេបានដាក់កាតព្វកិច្ចនេះលើពួកអ្នកជំនាន់មុនដែរ សង្ឃឹមថាពួកអ្នកនឹងកោតខ្លាច»។

8. អល់ឡោះទ្រង់បានមានព្រះបន្ទូលថា៖

﴿ شَهۡرُ رَمَضَانَ ٱلَّذِيٓ أُنزِلَ فِيهِ ٱلۡقُرۡءَانُ هُدٗى لِّلنَّاسِ وَبَيِّنَٰتٖ مِّنَ ٱلۡهُدَىٰ وَٱلۡفُرۡقَانِۚ فَمَن شَهِدَ مِنكُمُ ٱلشَّهۡرَ فَلۡيَصُمۡهُۖ وَمَن كَانَ مَرِيضًا أَوۡ عَلَىٰ سَفَرٖ فَعِدَّةٞ مِّنۡ أَيَّامٍ أُخَرَ ﴾ البقرة: ١٨٥

មានន័យថា៖ «ខែរ៉ម៉ាហ្ទនដែលគេបានបញ្ចុះគម្ពីរអាល់គួរអានមកក្នុងខែនេះជាមគ្គទេសក៏សម្រាប់មនុស្សលោក ហើយជាការបញ្ជាក់ពីសេចក្តីចង្អុលបង្ហាញ និងការបែងចែករវាងសច្ចភាពនិងអសច្ចភាព។ ដូច្នេះ អ្នកណាមានវត្តមានក្នុងខែនេះ គឺត្រូវតែបួស។ រីឯអ្នកណាដែលឈឺថ្កាត់ ឬត្រូវចេញដំណើរ គឺត្រូវបួសសងវិញនៅថ្ងៃផ្សេង»។

## ហេតុអ្វីចាំបាច់ត្រូវបួស(តម)ខែរ៉ាម៉ាឡន?

9. យើងបួសក្នុងខែរ៉ម៉ាហ្ទនដើម្បីគោរពប្រតិបត្តិតាមទទបញ្ជារបស់អល់ឡោះ។ អល់ឡោះទ្រង់បានបង្គាប់ប្រើដូច្នេះ ពីព្រោះទ្រង់ស្រលាញ់អ្នកដែលបួស។

10. យើងបួសដើម្បីអរគុណចំពោះទ្រង់ដែលបានប្រទានគម្ពីរអាល់គួរ-អានចុះមកក្នុងខែរ៉ម៉ាហ្ទនជាការបង្ហាញផ្លូវដល់ពួកយើងនិងមនុស្សទូទៅ។

11. អំណរគុណចំពោះទ្រង់ដែលបានជ្រើសរើសយើងនិងបង្កើតយើងជាអ្នកអ៊ីស្លាម។

12. អំណរគុណចំពោះទ្រង់ដែលបានផ្ដល់ឱកាសឱ្យយើងបានទន្លេញសូត្រ យល់ និងទទួលសេចក្ដីចង្អុលបង្ហាញពីគម្ពីរអាល់គួរអាន។

13. យើងបួសដើម្បីគ្រប់គ្រងខ្លួនយើងពីសេចក្ដីលោភលន់ហួបចុកដែលអល់ឡោះបានកកំណាត់ក្នុងខ្លួនប្រាណរបស់យើង។

14. ដើម្បីហាត់ពត់ខ្លួនឱ្យចេះលះបង់ចំណីអាហារ ទ្រព្យសម្បត្តិណាដែលអ៊ីស្លាមហាមប្រាមជាសេចក្ដីគោរពប្រតិបត្តិចំពោះបទបញ្ជារបស់អល់ឡោះជាម្ចាស់។

15. យើងបួសដើម្បីនឹកគិតដល់ជនក្រីក្រ អ្នកទន់ខ្សោយខ្វះខាតដែលពួកគេភាគច្រើនកំពុងរងគ្រោះអត់ឃ្លាន ហើយកូនចៅក្រុមគ្រួសាររបស់ពួកគាត់ក៏អត់ឃ្លានផងដែរ។ ដូច្នេះយើងចាំបាច់ធ្វើការដាក់ទានចែកចាយជូនដល់ពួកគេនូវអ្វីដែលអល់ឡោះបានប្រទានដល់យើង។

16. យើងបួសដើម្បីជៀសវាងពីភាពមមាញឹកនឹងកិលេសតណ្ហា យើងបង្កើនការយកចិត្តទុកដាក់ចំពោះផ្លូវចិត្តរបស់យើងតាមរយៈការខិតខំប្រឹងប្រែងគោរពប្រតិបត្តិចំពោះអល់ឡោះក្នុងខែគម្ពីរអាល់គួរអានដ៏ឧត្តុង្គឧត្តមនេះ។
17. ដើម្បីបង្កើនភាពស្មោះត្រង់ ដឹងពីការឃ្លាំមើលរបស់អល់ឡោះ សេចក្ដីអត់ធ្មត់ និងការគោរពប្រតិបត្តិចំពោះអល់ឡោះជាម្ចាស់។ម្យ៉ាងទៀតបួសមានសារប្រយោជន៍សម្រាប់សុខភាពផ្លូវកាយផងដែរ។
18. អល់ឡោះនឹងផ្ដល់ផលបុណ្យជាច្រើនដល់យើងទាំងអស់គ្នានៅថ្ងៃបរលោក។

# ជំពូកទី១៨
# ធ្វើបុណ្យហាជ្ជ

1. បុណ្យហាជ្ជគឺជាការធ្វើដំណើរទៅកៈហ្ពះនៅទីក្រុងម៉ាក្កះ ក្នុងបំណង ប្រតិបត្តិតាមបទបញ្ជារបស់អល់ឡោះ និងបំពេញអត្តសញ្ញាណ ពិសេសមួយចំនួននៅទីនោះ (ដើម្បីស្វែងយល់ឱ្យបានច្បាស់អំពី មេរៀននេះ សូមត្រលប់ទៅរកអានសៀវភៅឯកសារយោងស្តីអំពី ប្រធានបទនេះ)។
2. ការធ្វើហាជ្ជនេះជាកាតព្វកិច្ចត្រូវអនុវត្តឱ្យបានម្តងក្នុងមួយជីវិត លើអ្នកមូស្លីមដែលគ្រប់អាយុនិងមានលទ្ធភាព(ទាំងសុខភាពផ្លូវ កាយ និងទ្រព្យសម្បត្តិ)។
3. ដំណើរទៅធ្វើហាជ្ជនិងការប្រតិបត្តិផ្សេងៗទៀតបង្ហាញយ៉ាងច្បាស់ ពីរូបភាពតែមួយគត់នៃគោលការណ៍ឥស្លាម និងដើម្បីរំឭកដល់ គោលប្រតិបត្តិរបស់ពួកព្យាការីដូចជាអ៊ីព្រហ៊ីម អ៊ីស្មាអេល មូហាំម៉ាត់ (សូមសន្តិភាពកើតមានចំពោះពួកគាត់)។
4. ជាទូទៅគេប្រតិបត្តិបុណ្យហាជ្ជនៅពាក់កណ្តាលទី១នៃខែស៊ុលហា ជ្ជះ(ខែ១២នៃឆ្នាំហិចរ៉ោះ)។
5. គេប្រតិបត្តិការគោរពបុណ្យហាជ្ជដ៏ធំនេះនៅថ្ងៃទី៩នៃខែស៊ុលហាជ្ជះ គឺការឈប់សម្រាកនៅភ្នំអារ៉ាហ្វាតដែលពួកអ្នកប្រារព្ធបុណ្យហាជ្ជ ទៅជួបជុំគ្នានៅទីនោះ។ ចំនួនអ្នកចូលរួមទាំងអស់ពេលខ្លះអាចដល់ ទៅ២លាននាក់។
6. អ្នកធ្វើហាជ្ជទាំងអស់ប្រមូលផ្តុំគ្នានៅអារ៉ាហ្វាតដោយពួកគេធ្វើការបួង

សូងសុំការអភ័យទោសចំពោះ អល់ឡោះជាម្ចាស់ ប្រកាសការសារភាពកំហុស និងប្រាថ្នាចង់បានក្តីមេត្តាករុណានិងការអភ័យទោសពីទ្រង់។

7. ទាំងនេះជាការរំលឹកពួកយើងពីការជួបជុំគ្នាដ៏ធំមួយនៅថ្ងៃបរលោក។
8. ថ្ងៃបន្ទាប់(ថ្ងៃទី១០)ជាថ្ងៃបុណ្យដ៏ធំ គឺបុណ្យសំឡេះសត្វ ក្នុងថ្ងៃនោះអ្នកធ្វើបុណ្យហាជ្ជទាំងអស់ត្រូវសំលេះសត្វបូជារបស់ពួកគេក្រោយពីសំឡេះរួច ពួកគេបន្តទៅមឺក្កះ ពួកគេត្រូវដើរប្រទ័ក្សិណជុំវិញ( طواف )ក:ហ្ពះចំនួន៧ជុំ។
9. អ្នកមូស្លីមគ្រប់ទីកន្លែងត្រូវធ្វើការសំឡេះសត្វរបស់ពួកគេផងដែរដូចជា គោ ពពែ ក្រោយពីថ្វាយបង្គំនៃបុណ្យនេះរួច។
10. ការសំឡេះនេះដាក់ច្បាប់ឱ្យប្រតិបត្តិដើម្បីរំឭកដល់ការលះបង់ដ៏ធំរបស់ព្យាការីអ៊ីព្រហ៊ីម។ អល់ឡោះជាម្ចាស់ប្រើព្យាការីអ៊ីព្រហ៊ីមឱ្យសំឡេះកូនរបស់គាត់ព្យាការីអ៊ីស្មាអែល ហើយកាលនោះគាត់ស្ទើរតែសំឡេះកូនជាទីស្រលាញ់របស់គាត់មែនទែន។ នេះគ្រាន់តែជាការសាកល្បងពីភាពស្មោះត្រង់ និងការគោរពប្រតិបត្តិរបស់គាត់ចំពោះទ្រង់តែប៉ុណ្ណោះ។
11. នៅពេលណាអ្នកបានទៅធ្វើហាជ្ជរួចសព្វគ្រប់ អ្នកអាចទៅទស្សនាម៉ាស្ជិតព្យាការីនៅទីក្រុងម៉ាឌីណះមូណាវ៉ារ៉ស់ ហើយចូរអ្នកថ្វាយបង្គំនៅវិហារនោះ ពីព្រោះការថ្វាយបង្គំនៅក្នុងវិហារនោះមានផលបុណ្យធំធេងណាស់។
12. នៅពេលណាអ្នកបានទៅទីក្រុងម៉ាឌីណះមូណាវ៉ារ៉ស់ អ្នកគប្បីចូលមើលផ្នូររបស់ព្យាការីមូហាំម៉ាត់( សូមសន្តិភាពកើតមានចំពោះគាត់ )

និងផ្ទះរបស់សហការីរបស់គាត់ដ៏មហាថ្លៃថ្លា។ ការចូលមើលទស្សនាគឺជាប្រការដែលគេប្រើ ហើយសូមអ្នកឱ្យសទ្បាមស្វាគមដល់ពួកគាត់។

13. ដូច្នេះដែរការទៅទស្សនាវិហារអាល់អក់សរ នៅយ៉ារូសាឡឹម ជាប្រការគប្បីធ្វើផងដែរក្នុងអ៊ីស្លាម។ សូមអល់ឡោះទ្រង់មេត្តាជួយដល់ពួកអ្នកមូស្លីមក្នុងការសង្គ្រោះវិហារនេះឱ្យរួចផុតពីការត្រួតត្រារបស់ពួកជិហ្វឈ្លានពាន។

## ហេតុអ្វីត្រូវធ្វើហាជ្ជ?

14. ធ្វើហាជ្ជដើម្បីគោរពបទបញ្ជារបស់អល់ឡោះដ៏មហាខ្ពង់ខ្ពស់ ព្រោះទ្រង់បានដាក់កាតព្វកិច្ចមកចំពោះយើងទាំងអស់គ្នា។
15. ដើម្បីជាការដឹងគុណដែលទ្រង់បានប្រទានសុខភាពបរិបូរណ៍ កូនចៅ ទ្រព្យសម្បត្តិដល់ពួកយើងទាំងអស់គ្នា។
16. ដើម្បីលើកតម្កើងទ្រង់ដោយដើរជុំវិញកៈហ្ពះជាវិហាររបស់អល់ឡោះដ៏ជ្រះស្អាត។
17. កៈហ្ពះជាវិហារដំបូងបង្អស់ដែលគេបានសាងសង់លើកពផែនដីទុកជាទីសក្ការៈចំពោះអល់ឡោះ។ សាងសង់ដោយព្យាការីអ៊ីព្រហ៊ីមនិងបុត្ររបស់គាត់ព្យាការីអ៊ីស្មាអេល ដោយមានការបង្គាប់បញ្ជាពីអល់ឡោះជាម្ចាស់។
18. យើងធ្វើហាជ្ជដើម្បីបានថ្វាយបង្គំនៅកៈហ្ពះដែលជាគិបឡ័ត(ទិស) សម្រាប់ពួកអ្នកមូស្លីមទាំងអស់នៅលើសកលលោកឆ្ពោះតម្រង់ក្នុងពេលថ្វាយបង្គំ។
19. ដើម្បីឈប់នៅភ្នំអារ៉ាហ្វាត និងប្រតិបត្តិការសក្ការៈដ៏ឧត្តមនៅទីនោះ

ដូចជាវិញកចំពោះអល់ឡោះ ជម្រះខ្លួនរបស់យើងពីអំពើបាប និង សុំការលើកលែងទោសពីអល់ឡោះជាម្ចាស់។

20. ដើម្បីទស្សនាកន្លែងដែលព្យការីអ៊ីព្រហ៊ីមនិងព្យាការីអ៊ីស្មាអែលបានស្នាក់នៅនិងកន្លែងដែលពួកគាត់ទាំងពីរបានគោរពប្រតិបត្តិចំពោះអល់ឡោះជាម្ចាស់។

21. ដើម្បីចង់ឃើញទឹកដីពិសិដ្ឋដែលព្យាការីមូហាំម៉ាត់របស់យើងគាត់បានប្រសូតនិងធំដឹងក្តី ហើយបានទទួលវ៉ាហ៊ីនៅទីនោះ។ កន្លែងដែលគាត់បានទទួលការឈឺចាប់ និងបានតស៊ូក្នុងការផ្សព្វផ្សាយពន្លឺរបស់អល់ឡោះ។

22. ដើម្បីជួបជុំបងប្អូនអ៊ីស្លាមដែលមកពីគ្រប់ទិសទី ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ជីវភាពរស់នៅ និងការប្រកាន់ផ្សេងៗទៀតដែលច្បាប់លោកីយ៍បានបង្កើតឡើង។ នៅទីនោះយើងមើលឃើញពីសកលលោកអ៊ីស្លាម។

23. ដើម្បីហ្វឹកហាត់ចរិតអត់ធ្មត់ លះបង់ ពុះពារ ភាពសាមញ្ញនិងការប្រតិបត្តិផ្លូវចិត្តផ្សេងៗទៀត ដែលពួកយើងកំពុងតែត្រូវការបំផុត។

24. ដើម្បីជម្រះសម្អាតខ្លួនយើងពីអំពើបាបទាំងឡាយ យើងត្រលប់មកវិញដោយគ្មានអំពើបាប ហើយយើងចាប់ផ្តើមជីវិតរបស់យើងដោយភាពស្អាតស្អំ។ សង្ឃឹមថាយើងនឹងរក្សាភាពស្អាតស្អំនេះរហូតដល់ថ្ងៃដែលយើងទៅជួបនឹងអល់ឡោះជាម្ចាស់ ហើយយើងក្លាយក្រុមអ្នកដែលទទួលបាននូវការអាណិតស្រលាញ់ពីទ្រង់នៅក្នុងឋានសួគ៌ដ៏អមតៈ។

# ជំពូកទី១៩
# តើអ្នកអភិវឌ្ឍអ៊ីស្លាមរបស់អ្នកយ៉ាងដូចម្តេច ?

1. នៅពេលអ្នកប្រកាសខ្លួនព្រមចូលអ៊ីស្លាម មានន័យថា អ្នកកំពុងបើកទំព័រសក្នុងបញ្ជីអំពើល្អរបស់អ្នក។
2. រីឯអ្វីៗដែលបានកន្លងហួសនៃអំពើអាក្រក់ទាំងប៉ុន្មាននោះសង្ឃឹមថាអល់ឡោះទ្រង់នឹងអភ័យទោសដល់អ្នកដោយសារការចូលអ៊ីស្លាមរបស់អ្នក។
3. ប្រាកដណាស់ នៅពេលអ្នកបានចូលអ៊ីស្លាម មានន័យថាអ្នកបានកើតសាជាថ្មីក្នុងសាសនាអ៊ីស្លាម។
4. ចំពោះអ្នកត្រូវតែអភិវឌ្ឍខ្លួនឯងនិងធ្វើឱ្យខ្លួនឯងរីកលូតលាស់ក្នុងឥស្លាម។ តើត្រូវធ្វើយ៉ាងដូចម្តេច ?

## ទី១ បង្កើនការយល់ដឹងរបស់អ្នកអំពីអ៊ីស្លាមៈ

1. ដោយសូត្រអាល់គួរអាន
2. អានអំពីការបកស្រាយ( តាហ្វសៀរ )អាល់គួរអាន។
3. អានបណ្តាហាទីសដែលគេបានពាំនាំពីព្យាការីមូហាំម៉ាត់( សូមសន្តិភាពកើតមានចំពោះគាត់ )។
4. អានជីវៈប្រវត្តិរបស់គាត់
5. អានជីវប្រវត្តមេដឹកនាំអ៊ីស្លាមនិងជីវប្រវត្តរបស់អ្នកចេះដឹងមុនៗដែលពួកគេបានផ្សព្វផ្សាយសាសនាអ៊ីស្លាមរហូតបានសុសសាយពេញលើសកលលោក។

6. ចូលរួមថ្វាយបង្គំថ្ងៃសុក្រ( សាឡាតយ៉ំអាត់ ) ដើម្បីស្តាប់បទទូន្មានប្រៀនប្រដៅ និងដើម្បីថ្វាយបង្គំជាមួយនឹងបងប្អូនអ៊ីស្លាម។
7. ចូលរួមថ្វាយបង្គំថ្ងៃបុណ្យទាំងពីរ និងស្តាប់ពាក្យទូន្មានប្រៀនប្រដៅរបស់អ៊ីម៉ាំ។
8. ថ្វាយបង្គំទាំង៥ពេលក្នុងវិហារអ៊ីស្លាម នៅពេលដែលគ្មានបញ្ហាលំបាកអ្វីកើតឡើងចំពោះអ្នក។
9. ចូលរួមក្នុងកម្មវិធីនានាដែលបង្រៀនអំពីសាសនាអ៊ីស្លាម។
10. ព្យាយាមទំនាក់ទំនងជាមួយអ្នកដែលមានលទ្ធភាពនៃពួកអ្នកដែលមានចំណេះដឹង អ្នកដឹកនាំវិហារ និងគ្រូបង្រៀនសាសនា ហើយចូរណែនាំខ្លួនរបស់អ្នកដល់ពួកគេ និងសួរពួកគេពីអ្វីដែលអ្នកមិនទាន់យល់ច្បាស់នៃកាតព្វកិច្ចសាសនាអ៊ីស្លាម។ ច្បាស់ណាស់បុគ្គលដែលអ្នកទៅសួរនោះគាត់នឹងសប្បាយចិត្ត រីករាយក្នុងការបកស្រាយជូនដល់អ្នកជាមិនខាន។
11. ព្យាយាមរាប់អានមិត្តភ័ក្តិដែលជាអ្នកមូស្លីម ចេះដឹងអំពីសាសនាអ៊ីស្លាម ដើម្បីចង្អុលបង្ហាញអ្នក ពន្យល់អ្នកពីអ្វីដែលអ្នកពុំទាន់យល់ច្បាស់នៃកាតព្វកិច្ចសាសនាអ៊ីស្លាម។
12. ចូរអានប្រភពគ្រឹះនៃសាសនាអ៊ីស្លាម( គម្ពីរអាល់គួរអាន និងក្បួនច្បាប់របស់ព្យាការី) ព្រមទាំងសៀវភៅដែលមានជំនឿទុកចិត្តបកស្រាយអំពីអ៊ីស្លាម ដើម្បីបង្កើនចំណេះដឹងរបស់អ្នក។
13. អ្នកនឹងបានយល់ជាច្រើនអំពីវិន័យអ៊ីស្លាម របៀបរបបនៃប្រតិបត្តិទាំងឡាយ វិន័យគ្រួសារ ការទំនាក់ទំនង សុជីវធម៌ សេដ្ឋកិច្ច ហើយនិងកិច្ចការទូទៅ។

14. អ្នកនឹងជ្រាបពីមាគ៌ាអ៊ីស្លាមនិងទស្សនរបស់វាដែលស្ដីអំពីការបង្កើតភពផែនដី មនុស្សលោក និង ការរស់នៅ។
15. អ៊ីស្លាមមិនត្រឹមតែជាសាសនាប៉ុណ្ណោះទេ តែជាប្រព័ន្ធគ្រប់គ្រងសង្គម ច្បាប់រដ្ឋ និងជាផ្លូវសម្រាប់ជីវិតផងដែរ។

## ទីពីរ ៖ បន្ថែមការប្រតិបត្តិអំពើល្អ

16. ព្យាយាមធ្វើនូវទង្វើល្អបន្ថែមពីលើទការប្រតិបត្តិទាំង៥ដែលបាននិយាយកន្លងមក ឧទាហរណ៍៖
17. ធ្វើការថ្វាយបង្គំបន្ថែមពីលើការថ្វាយបង្គំទាំង៥ពេល។
18. ឬជួយជនក្រីក្រនិងអ្នកដែលខ្វះខាតអត់ឃ្លានបន្ថែមពីលើទ្រព្យដែលច្បាប់អ៊ីស្លាមបង្គាប់ឱ្យបរិច្ចាគ ឬជួយពួកគេក្នុងការរៀបចំកិច្ចការចាំបាច់ដែលពួកគេពុំមានលទ្ធភាពធ្វើ។
19. ឬបួស( តម )បន្ថែមពីលើការបួសក្នុងខែរ៉ម៉ាហ្ទន។
20. ឬចូលរួមក្នុងគម្រោងសង្គមកិច្ចក្នុងគោលបំណងចូលរួមអភិវឌ្ឍន៍សង្គមអ៊ីស្លាម។
21. ឬអំពាវនាវមិត្តភ័ក្តិណាម្នាក់ឱ្យចូលអ៊ីស្លាម។

# ជំពូកទី២០
# តើអ្នករក្សាអ៊ីស្លាមរបស់អ្នកយ៉ាងដូចម្តេច?

1. នៅពេលដែលអ្នកបានចូលអ៊ីស្លាម មានន័យថា អ្នកបានរក្សាទុកអំពើល្អជាច្រើនសម្រាប់ខ្លួនអ្នក។
2. អ្នកប្រៀបដូចជាអ្នកដែលដែលមានសំណាងទទួលបានកំណប់ដ៏មានតម្លៃ។
3. អ្នកដែលមានកំណប់ដ៏មានតម្លៃនេះ ប្រាកដជាមានសត្រូវជាច្រើនព្យាយាមមកលួចយកកំណប់របស់អ្នក។
4. ដូច្នោះដែរ អ្នកបានទទួលកំណប់អ៊ីស្លាម។
5. គង់តែមានមនុស្សមួយចំនួននឹងព្យាយាមរារាំងអ្នកពីសាសនាថ្មីរបស់អ្នក។
6. ពួកគេទាំងនោះជាសត្រូវរបស់អល់ឡោះ។
7. សត្រូវរបស់អល់ឡោះគឺពួកបិសាចជាមនុស្សមនុស្សដូចគ្នា និងព្រាយបិសាច។
8. រីឯព្រាយបិសាចមនុស្សគឺពួកគេព្យាយាមសាកល្បងនិយាយាប្រមាថមើលងាយអ្នក។
9. ឬព្យាយាមបញ្ចុះបញ្ចូលអ្នកដោយយកលុយមកទិញទឹកចិត្តរបស់អ្នកឱ្យចាកចេញពីសាសនារបស់អ្នក។
10. គេនិយាយប្រាប់អ្នកថា អ៊ីស្លាមជាសាសនាបែបនេះបែបនោះ ហើយ
11. ពួកគេនិយាយាបន្លប់ អ្នកដើម្បីធ្វើឱ្យអ្នកច្របូកច្របល់កើងក្តីមន្ទិលសង្ស័យ។

12. ចូរជ្រាបចុះអល់ឡោះបានមានព្រះបន្ទូលថា៖

﴿ وَلَا يَأْتُونَكَ بِمَثَلٍ إِلَّا جِئْنَاكَ بِالْحَقِّ وَأَحْسَنَ تَفْسِيرًا ﴾ ٣٣ الفرقان: ٣٣

មានន័យថា៖ «ហើយពួកគេនឹងមិននាំមកនូវភស្តុតាងឬលេសសំអាងណាមួយ លើកលែងតែយើងប្រទានជូនដល់អ្នកនូវចម្លើយដ៏សច្ចៈត្រឹមត្រូវ ហើយជាការបកស្រាយដ៏ប្រសើរជាទីបំផុត»។

13. ចូរអ្នកសួរពួកអ្នកប្រាជ្ញរបស់អ៊ីស្លាមពីចម្លើយដែលអល់ឡោះបានប្រទានចុះមកក្នុងគម្ពីរអាល់គួរអាន ចំពោះរាល់ការចម្ងល់សង្ស័យរបស់អ្នក។
14. រីឯព្រាយបិសាច(យ៉ិន)វិញ ពួកគេបានពង្វក់ដួងចិត្តរបស់អ្នកឱ្យវិលវល់ ពួកគេខ្សឹបប្រាប់អ្នកថា៖តើអ្នកបោះបង់សាសនារបស់អ្នក និងបោះបង់សាសនាជីដូនជីតា ហើយជ្រើសរើសយកសាសនាដទៃឬ?
15. តើអ្នកតាមសាសនាដែលបង្គាប់ប្រើឱ្យថ្វាយបង្គំ(សាឡាត) បួស(តម) និងបរិច្ចាគ(ហ្សាកាត)ឬ? សាសនាដែលហាមអ្នកមិនឱ្យផឹកស្រា។ល។?
16. ចូរជ្រាបចុះថា រាល់មនុស្សទាំងអស់តែងប្រទះឃើញខ្លួនឯងដើរតាមសាសនាដែលឪពុកម្ដាយរបស់គេបានដើរតាម ហើយគេធំដឹងក្ដីក្នុងសាសនានោះ។
17. ទាំងពួកអ្នកដើរលើផ្លូវត្រូវ និងអ្នកដើរលើផ្លូវខុស។
18. ក៏ប៉ុន្តែជាបញ្ហានៅត្រង់ តើសាសនាណាមួយដែលពិត ហើយសាសនាណាមួយដែលវង្វេង?
19. ជាពិតណាស់ អ៊ីស្លាមជាសាសនាដ៏ពិតប្រាកដ ជ្រះស្អាតពីអបិយជំនឿទាំងឡាយ ជ្រះស្អាតពីអំពើពហុទេពក្នុងការគោរពសក្ការៈ

ចំពោះព្រះជាម្ចាស់។

20. ជាសាសនាដែលមានជំនឿចំពោះម្ចាស់តែមួយគត់ និងស្មោះត្រង់ចំពោះទ្រង់។

21. នៅពេលអ្នកមានអារម្មណ៍ថា មានព្រាយបិសាចមកយាយីអ្នក ចូរអ្នកសូត្រថា៖

﴿ رَّبِّ أَعُوذُ بِكَ مِنۡ هَمَزَٰتِ ٱلشَّيَٰطِينِ ٩٧ وَأَعُوذُ بِكَ رَبِّ أَن يَحۡضُرُونِ ٩٨ ﴾ المؤمنون: ٩٧ - ٩٨

មានន័យថា៖ «បពិត្រព្រះជាម្ចាស់របស់ខ្ញុំ សូមទ្រង់មេត្តាគាំពារខ្ញុំពីការល្បួងរបស់ពួកព្រាយបិសាច។ សូមទ្រង់មេត្តាគាំពារខ្ញុំពីការមកយាយីរបស់ពួកគេក្នុងកិច្ចការងាររបស់ខ្ញុំ»។

22. ចូរសូត្រផងដែរជំពូកអាល់ហ្វាឡឹក (سورة الفلق)និងជំពូកអាន់ណើស (سورةالناس)

(សូមអានក្នុងមេរៀនបន្ថែម)។

# ជំពូកទី២១
# តើអ្នកអំពាវនាវអ្នកដទៃឱ្យចូលអ៊ីស្លាមយ៉ាងដូចម្ដេច ?

1. ព្យាការីមូហាំម៉ាត់បានមានប្រសាសថា៖

قال الرسول صلى الله عليه وسلم : ( فوالله لأن يهدي الله بك رجلاً واحداً خير لك من أن يكون لك حمر النَّعَم ) رواه البخاري، ومسلم

មានន័យថា«ខ្ញុំសូមស្បថចំពោះអល់ឡោះជាម្ចាស់ បើអល់ឡោះទ្រង់ប្រទានសេចក្ដីចង្អុលបង្ហាញដល់នូវបុរសម្នាក់ចូលអ៊ីស្លាមដោយសារអ្នក វាប្រសើរចំពោះអ្នកជាងអ្នកមានសត្វសត្វអូដ្ឋថ្លៃមួយក្បាលទ្រព្យដែលមានតម្លៃបំផុតនៅអារ៉ាប់កាលសម័យបុរាណ )››។

2. គាត់បានប្រសាសន៍ទៀតថា៖

وقال صلى الله عليه وسلم أيضا : (من دعا إلى هدى كان له من الأجر مثل أجور من تبعه لا ينقص ذلك من أجورهم شيئاً )

មានន័យថា‹‹អ្នកណាដែលបានអំពាវនាវទៅរកសេចក្ដីចង្អុលបង្ហាញ អ្នកនោះទទួលផលបុណ្យដូចអ្នក ដែលបានធ្វើតាមគេដែរ គ្មានខាតបង់ផលបុណ្យរបស់ពួកគេអ្វីបន្តិចឡើយ››។

3. ចូរយកចិត្តទុកក្នុងការអំពាវនាវទៅរកអ៊ីស្លាមចំពោះបុគ្គលមិនមែនមូស្លីមដែលអ្នកស្គាល់។
4. ចាប់ផ្ដើមពីសាច់ញាតិដែលជិតជាងគេបំផុតដូចជាឪពុកម្ដាយរបស់អ្នក ប្រពន្ធ ប្ដី កូនប្រុស កូនស្រី បងប្អូនប្រុសស្រី អ្នកជិតខាង មិត្តភ័ក្តិ។
5. អល់ឡោះជាម្ចាស់បានមានព្រះបន្ទូលដល់ព្យាការីរបស់គាត់ថា ៖

﴿ وَأَنذِرْ عَشِيرَتَكَ ٱلْأَقْرَبِينَ ﴿٢١٤﴾ ﴾ الشعراء: ٢١٤

មានន័យថា៖(ចូរអ្នកក្រើនរំលឹកដាស់តឿនដល់សាច់ញាតិរបស់អ្នក ដែលជិតបំផុត)។

6. ចូរបង្ហាញប្រាប់ពួកគេអំពីសាសនាពិត ហើយបញ្ចុះបញ្ចូលពួកគេឱ្យពេញចិត្តនឹងសាសនានេះ។
7. ផ្ដល់ដំណឹងរីករាយដល់ពួកគេ ពីអ្វីដែលអល់ឡោះបានប្រទានដល់ពួកគេក្នុងលោកីយ៍នេះហើយនិងក្នុងបរលោក ដោយពួកគេដើរតាមគន្លងអ៊ីស្លាម។
8. ចូរដាស់តឿនពួកគេឱ្យដឹងថា អល់ឡោះទ្រង់ខឹងចំពោះពួកគេនៅពេលដែលពួកគេមិនព្រមមានជំនឿចំពោះគម្ពីរអាល់គួរអានដែលទ្រង់បានបញ្ចុះមកជាមគ្គទេសក៍សម្រាប់មនុស្សលោកទាំងមូល។
9. ឬពួកគេមិនមានជំនឿចំពោះព្យាការីមូហាំម៉ាត់ដែលអល់ឡោះបានបញ្ជូនគាត់មកជាក្ដីមេត្តាសម្រាប់សកលលោកទាំងមូល។
10. ចូរអំពាវនាវដោយក្ដីស្រលាញ់ និងស្មោះត្រង់។
11. ខ្លួនអ្នកផ្ទាល់ត្រូវធ្វើគំរូល្អដោយប្រកាន់នូវអត្តចរិតថ្លៃថ្នូរ។
12. ចូរប្រញាប់ប្រញាល់ធ្វើអំពើល្អ និងជាប្រយោជន៍រួម។
13. បើសិនជាអ្នកធ្វើដូច្នេះអ្នកនឹងក្លាយជាអ្នកអំពាវនាវមករកអ៊ីស្លាមដោយទង្វើនិងសម្ដីរបស់អ្នក។
14. មិត្តភ័ក្តិរបស់អ្នកនឹងទទួលការអំពាវនាវរបស់អ្នកយ៉ាងរហ័ស ប្រសិនបើអល់ឡោះទ្រង់បើកផ្លូវចង្អុលបង្ហាញដល់ពួកគេ។
15. ពួកគេនឹងដឹងអ្វីដែលចេញពីមាត់របស់អ្នកសុទ្ធតែជាការពិត។
16. ពួកគេនឹងទទួលយកអ៊ីស្លាម ស្រលាញ់ចូលចិត្ត ហើយពួកគេនឹង

ស្រលាញ់ចូលចិត្តអ្នកផងដែរ។

17. អ្នកចាំបាច់ត្រូវម៉ត់ចត់ក្នុងការអំពាវនាវ និងបង្រៀន។ ចូរអ្នកនិយាយផ្សព្វផ្សាយនៅគ្រប់ទីកន្លែងទាំងអស់ដែលសមស្រប។

18. ដោយមានពាក្យស្លោកអារ៉ាប់មួយពោលថា៖ (រាល់សម្ដីនីមួយៗអស្រ័យទៅនឹងបរិបទ)។

19. អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖

﴿ ٱدۡعُ إِلَىٰ سَبِيلِ رَبِّكَ بِٱلۡحِكۡمَةِ وَٱلۡمَوۡعِظَةِ ٱلۡحَسَنَةِۖ وَجَٰدِلۡهُم بِٱلَّتِي هِيَ أَحۡسَنُۚ إِنَّ رَبَّكَ هُوَ أَعۡلَمُ بِمَن ضَلَّ عَن سَبِيلِهِۦ وَهُوَ أَعۡلَمُ بِٱلۡمُهۡتَدِينَ ١٢٥ ﴾

النحل: ١٢٥

មានន័យថា៖ «ចូរអ្នកអំពាវនាវទៅកាន់ផ្លូវព្រះជាម្ចាស់របស់អ្នកដោយគតិបណ្ឌិត និងការទូន្មានប្រៀប្រដៅដ៏ល្អ ប្រពៃ ហើយចូរអ្នកជជែកជាមួយនឹងពួកគេដោយអ្វីដែលល្អប្រសើរ។ ប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នកមហាដឹងចំពោះអ្នកដែលវង្វេងពីផ្លូវរបស់ទ្រង់ ហើយទ្រង់មហាដឹងចំពោះអ្នកដែលទទួលបាននូវសេចក្ដីចង្អុលបង្ហាញ)។

20. បើសិនជាអ្នកមិនទាន់ចេះភាសារអារ៉ាប់ជ្រៅជ្រះទេនោះ ចូរអ្នកស្រាវជ្រាវសិក្សាបន្ថែម ដើម្បីស្វែងយល់អំពីសាសនាអ៊ីស្លាមឱ្យដឹងកាន់តែច្បាស់ពីប្រភពដើមរបស់វា។

21. នៅពេលនោះបើសិនជាអ្នកនិយាយអំពីសាសនាអ៊ីស្លាមអ្នកនឹងនិយាយពីចំណេះដឹងផ្ទាល់នៃព្រះបន្ទូលរបស់អល់ឡោះ និងពាក្យប្រសាសន៍របស់អ្នកនាំសាររបស់អល់ឡោះ និងសំម្ដីអ្នកប្រាជ្ញអ៊ីស្លាម។

22. ចូរផ្តល់សៀវភៅនេះមួយច្បាប់ជូនដកលអ្នកណាដែលអ្នកពេញចិត្ត ចង់អ្នកនឹងអំពាវនាវគេឱ្យចូលអ៊ីស្លាមដើម្បីជាជំនួយដល់អ្នកក្នុងការបកស្រាយពន្យល់។

## ជំពូកទី២២
## ប្រការដែលគេហាមឃាត់

1. ប្រាកដណាស់ អល់ឡោះជាម្ចាស់បាបបញ្ញត្តិច្បាប់ដល់យើងទាំងអស់គ្នានៅក្នុងគម្ពីរអាល់គួរអាន និង ទំនៀមទំលាប់(សុណ្ណះ) ជាច្រើនរបស់ព្យាការីមូហាំម៉ាត់។
2. ក្នុងនោះមានប្រការចាំបាច់ត្រូវតែធ្វើ និងប្រកាចាំបាច់ត្រូវតែបោះបង់។
3. អ្វីដែលជាប្រការចាំបាច់ត្រូវតែធ្វើនោះគឺយើងបានបកស្រាយវារួចមកហើយក្នុងមេរៀនមុនៗ។
4. រីឯប្រកាចាំបាច់ត្រូវតែបោះបង់ នោះគឺយើងនឹងនិយាយអំពីការបកស្រាយដូចខាងក្រោម៖

### ទីមួយ៖ ចំណីអាហារដែលគេហាមឃាត់

5. សាកសព៖ សាកសពសត្វពាហនៈដែលរស់នៅលើគោក ទោះបីសត្វនោះស្លាប់ដោយដាច់ខ្យល់(មិនបានសំឡេះតាមក្បួនច្បាប់អ៊ីស្លាម) ឬស្លាប់ដោយគេចងក ឬស្លាប់ដោយត្រូវគេប្រានទំលាក់ពីទីខ្ពស់ ឬត្រូវសត្វសាហាវខាំស៊ី ហើយស្លាប់ដោយមិនទាន់បានសំឡេះ។
6. ក៏ដូចគ្នាដែរ អ្នកដែលសំឡេះនោះមិនមែនជាអ្នកមូស្លីម ក្រៅពី

ណាសរ៉នី(គ្រិស្ទាន) និងយ៉ាហូឌី(ជិហ្វ)។

7. រីឯសាកសពសត្វដែលរស់នៅក្នុងទឹកគេពុំបានហាមឃាត់ទេ មានន័យថាយើងអាចហូបបាន។
8. ឈាមដែលហូរចេញពីសត្វគេសំឡេះ។
9. សាច់ជ្រូក។
10. សត្វដែលគេសំលេះមិនបានសូត្រព្រះនាមអល់ឡោះ ឬគេសំឡេះទុកបូជាក្រៅពីអល់ឡោះ។
11. សាច់សត្វសាហាវដូចជាសត្វតោ ខ្លា ឆ្កែ ឬសាច់សត្វស្លាបកំណាចដូចជាស្ទាំង ឥន្ទ្រី។
12. សាច់សត្វលាស្រុក។
13. សាច់សត្វដែលស៊ីចំណីកខ្វក់ស្អុយរលួយ លុះត្រាតែយើងឃុំវាទុកដើម្បីឱ្យចំណីស្អាតវាស៊ីមួយរយៈកាលគ្រប់គ្រាន់មុននឹងសំឡេះវាហូប។
14. រាល់ម្ហូបចំណីណាដែលប្រលាក់របស់កខ្វក់ លុះត្រាណាយើងលាងសម្អាតវាសិនបើអាច។
15. ស្រា គ្រឿងញៀន និងវត្ថុទាំងឡាយដែលមានជាតិស្រវឹង ។
16. រាល់ចំណីណាដែលធ្វើអោយគ្រោះថ្នាក់ដល់សុខភាពរាង្គកាយដូចជាថ្នាំពុលជាដើម។

## ទីពីរ ៖ ទង្វើដែលគេហាមឃាត់

គឺជាទង្វើដែលអល់ឡោះស្អប់ខ្ពើម ទ្រង់ក្រោធខឹង ហើយទ្រង់នឹងទារុណកម្មចំពោះអ្នកដែលប្រព្រឹត្ត។

17. គោរពម្ចាស់ផ្សេងរួមជាមួយអល់ឡោះ ( ស្ហ៊ីរិក ) អកតញ្ញូចំពោះឪពុកម្ដាយ។
18. ធ្វើសាក្សីបោកប្រាស់កាពារជនទុច្ចរិត។
19. សម្លាប់ជីវិត ដែលច្បាប់អ៊ីស្លាមបានហាម លើកលែងតែខុសនឹងច្បាប់ឥស្លាម។
20. ប្រព្រឹត្តអំពើផិតជាមួយអ្នកដែលច្បាប់អ៊ីស្លាមបានហាមឃាត់។
21. ការលួច ប្លន់។
22. កេងប្រវ័ញ្ចទ្រព្យសម្បត្តិក្មេងកំព្រា។
23. រត់គេចចេញពីសង្គ្រាមប្រយុទ្ធប្រឆាំងជាមួយនឹងសត្រូវ។
24. ចោទប្រកាន់អំពើផិតក្បត់ចំពោះបុរស និងស្ត្រីដែលស្អាតស្អំ។
25. បើកបង្ហាញកេរ្តិ៍ខ្មាស ( عورة )[4] នៅចំពោះមុខមហាជន លើកលែងតែដើម្បីព្យាបាល។
26. កេងប្រវ័ញ្ចទ្រព្យសម្បត្តិអ្នកដទៃដោយអំពើទុច្ចរិត ឬសូកប៉ាន់ បោកប្រាស់។
27. ប្រើប្រាស់ការសូកប៉ាន់ដើម្បីកេងប្រវ័ញ្ចទ្រព្យសម្បត្តិអ្នកដទៃ ឬដើម្បីយកសម្បត្តិអ្នកដទៃធ្វើជាកម្មសិទ្ធិខ្លួនដោយខុសច្បាប់។
28. រៀបការជាមួយម្ដាយខ្លួនឯង ឬកូនស្រីខ្លួនឯង ឬរៀបការជាមួយមាបង្កើត ឬក្មួយស្រីបង្កើត ជាបងប្អូនបង្កើតឬរួមម៉ែដោះ ឬក៏ជាប្រពន្ធរបស់ឪពុក ឬក៏កូន ឬម្ដាយក្មេក ឬកូនរបស់ប្រពន្ធជាដើម។

---

[4] ពាក្យ (عورة) គឺជាផ្នែកមួយនៃរាងកាយរបស់ប្រុស និងស្រីដែលត្រូវតែបិទបាំង។ សម្រាប់បុរស គឺចាប់ពីផ្ចិតរហូតដល់ជង្គង់ រីឯស្ត្រីវិញគឺខ្លួនប្រាណទាំមូល លើកលែងតែមុខ និងប្រអប់ដៃទាំងពីរ។

29. បុរសមូស្លីមកុំរៀបការជាមួយស្ត្រីដែលជាពួកការហ្វៀត(ប្រឆាំង) លើកលែងតែពួកណាសរ៉ានី(គ្រិស្ទាន) និងពួកយ៉ាហូដ(ជីហ្វ)
30. កុំរៀបការស្ត្រីអ៊ីស្លាមឱ្យទៅបុរសកាហ្វៀរ ទោះបីជាណាសរ៉ានី (គ្រិស្ទាន) ឬយ៉ាហូឌី(ជីហ្វ)។

## ជំពូកទី២៣
## អាវលីយ៉ាក[5]របស់អល់ឡោះ
## (សំណព្វចិត្តរបស់អល់ឡោះ)

1. សំណព្វចិត្តរបស់អល់ឡោះគឺជាអ្នកដែលអល់ឡោះទ្រង់ស្រលាញ់ សព្វព្រះទ័យចំពោះពួកគេ ហើយពួកគេក៏ស្រលាញ់អល់ឡោះផងដែរ។
2. ពួកគេគឺជាអ្នកប្រតិបត្តិអំពើកុសលធម៌ មានជំនឿចំពោះអល់ឡោះ និងប្រតិបត្តិតាមបញ្ញារបស់ទ្រង់។
3. អល់ឡោះតបស្នងដល់ពួកគេនូវការរស់នៅដ៏មានបរមសុខសុភមង្គល នៅក្នុងលោកិយនេះ ហើយពួកគេនឹងបានរស់នៅជិតខាងអល់ឡោះ ក្នុងថ្ងៃបរលោកនៅឋានសួគ៌ដ៏ឧត្តុង្គឧត្តម។
4. ពូកគេ(ពួកអៅលីយ៉ាក)គ្មានលទ្ធភាពអាចជួយសង្គ្រោះអ្នកណាម្នាក់

[5] (អាវលីយ៉ាក)ពហុវចនៈនៃពាក្យ(វ៉ាលីយ៍)ជាបច្ចេកសព្ទអ៊ីស្លាមមានន័យកំណត់ បានសេចក្តីថាជាអ្នកមូស្លីមដែលបានសម្អាតចិត្តរបស់គេដោយសេចក្តីជ្រះថ្លាសម្រាប់បទបញ្ញារបស់អល់ឡោះក្នុងអត្ថន័យដ៏ទូលំទូលាយនិងស៊ីជម្រៅ។
ក៏ប៉ុន្តែបច្ចេកសព្ទនេះត្រូវបានអ្នកមូស្លីមខ្លះប្រើខុស។ ដែលពួកគេបានទទួលឥទ្ធិពលពីក្រៅមិនមែនមានលក្ខណៈជាអ៊ីស្លាម។
ដូច្នេះពូកគេសំដៅទៅលើជនចំឡែកដែលប្រកបដោយអាថ៌កំបាំងអះ
អាងថាខ្លួនគេមានអានុភាពក្នុងការបង្កើតឱ្យមានភាពអច្ឆរិយៈ។ ឧទាហរណ៍ដូចជាពួកអ្នកប្រាជ្ញលោក
ខាងលិចដែលសិក្សាអំពីឥស្លាមយល់ថាថាពាក្យ(អាវលីយ៉ាក)ស្រដៀងនឹងពាក្យ‹‹អាល់គុដស៊ីន››(សន្តបុគ្គល)
ក្នុងសាសនាគ្រិស្ទាន អំណះអំណាងនេះគ្មានគោលគ្រឹះការពិតអ្វីទាំងអស់។

បានឡើយ ក្រោយពីពួកគេបានស្លាប់ ហើយក៏គ្មានដែរក្នុងឆាកជីវិតរបស់ពួកគេ លើកលែងតែតាមមូលហេតុជម្មតាប៉ុណ្ណោះ។

5. ដូចអល់ឡោះបានមានបន្ទូលថា៖

﴿ أَلَآ إِنَّ أَوۡلِيَآءَ ٱللَّهِ لَا خَوۡفٌ عَلَيۡهِمۡ وَلَا هُمۡ يَحۡزَنُونَ ٦٢ ٱلَّذِينَ ءَامَنُواْ وَكَانُواْ يَتَّقُونَ ٦٣ لَهُمُ ٱلۡبُشۡرَىٰ فِي ٱلۡحَيَوٰةِ ٱلدُّنۡيَا وَفِي ٱلۡأٓخِرَةِۚ لَا تَبۡدِيلَ لِكَلِمَٰتِ ٱللَّهِۚ ذَٰلِكَ هُوَ ٱلۡفَوۡزُ ٱلۡعَظِيمُ ٦٤ ﴾ يونس: ٦٢ - ٦٤

មានន័យថា៖«ប្រាកដណាស់ សំណព្វចិត្តរបស់អល់ឡោះ គឺពួកគេគ្មានភាពភ័យខ្លាច ហើយក៏គ្មានកើតទុក្ខព្រួយអ្វីដែរ។ ពួកអ្នកដែលមានជំនឿ ហើយគោរពកោតខ្លាច។ សម្រាប់ពួកគេនោះគឺដំណឹងរីករាយនៅលើលោកីយ៍ និងនៅថ្ងៃបរលោក ព្រះបន្ទូលរបស់អល់ឡោះគ្មានការផ្លាស់ប្តូរឡើយ។ នោះគឺជាការជោគជ័យដ៏ធំធេងជាទីបំផុត)។

6. ចូរកសាងខ្លួនជាអ្នកអ៊ីស្លាមដ៏ល្អនោះអ្នកនឹងក្លាយជាអ្នកដែលនៅក្នុងចំណោមពួកគេ។

7. អល់ឡោះមានបន្ទូលថា៖

﴿ وَمَن يُطِعِ ٱللَّهَ وَٱلرَّسُولَ فَأُوْلَٰٓئِكَ مَعَ ٱلَّذِينَ أَنۡعَمَ ٱللَّهُ عَلَيۡهِم مِّنَ ٱلنَّبِيِّـۧنَ وَٱلصِّدِّيقِينَ وَٱلشُّهَدَآءِ وَٱلصَّٰلِحِينَۚ وَحَسُنَ أُوْلَٰٓئِكَ رَفِيقٗا ٦٩ ﴾ النساء: ٦٩

មានន័យថា៖ ‹‹ អ្នកដែលគោរពប្រតិបត្តិចំពោះអល់ឡោះនិងអ្នកនាំសារ ពួកគេស្ថិតនៅជាមួយនឹងពួកអ្នកដែលទ្រង់បានប្រទានពរជ័យដល់ពួកគេនៃពួកអ្នកនាំសារ ពួកអ្នកមានជំនឿស្មោះត្រង់ ពួកអ្នកពលីជីវិតក្នុងផ្លូវអល់ឡោះ និងពួកអ្នកដែលសាងនូវកុសលធម៌ ហើយពួកគេជាគូកនដ៏ល្អប្រសើរជាទីបំផុត››។

8. ពួកអ្នកដែលជាសំណព្វចិត្តរបស់អល់ឡោះមានដូចជាពួកព្យាការីរបស់ទ្រង់ដ៏ថ្លៃថ្លា។
9. ពួកសហការីរបស់ព្យាការីដែលពួកគេមានជំនឿយ៉ាងមុតមាំចំពោះពួកព្យាការី។
10. ពួកសហការីរបស់ព្យាការីមូហាំម៉ាត់(សូមសន្តិភាពកើតមានចំពោះគាត់)និងភរិយាៗរបស់គាត់។
11. ពួកសហការីដ៏ល្អបំផុតរបស់គាត់ គឺអ្នកទាំងដប់ដែលគេផ្តល់ដំណឹងល្អឱ្យបានចូលឋានសួគ៌។
12. ពួកគេទាំងនេះគឺជាសហការីដែលបានគេជ្រើសរើសជាអ្នកជាមនុស្សដ៏ល្អប្រសើរជាទីបំផុតដោយការចូលឥស្លាមមុនគេ មានជំហររឹងមាំហើយហ៊ានលះបង់ដើម្បីអ៊ីស្លាម។
13. ពួកអ្នកដែលមានឋានៈខ្ពស់ជាងអ្នកទាំងដប់នោះគឺ ពួកខលីហ្វះទាំងបួន(الخلفاء الراشدين)ដែលពួកអ្នកមូស្លីមទាំងអស់នាសម័យនោះបានជ្រើសរើសលើកពួកគាត់ជាអ្នកដឹកនាំអាណាចក្រអ៊ីស្លាមបន្ទាប់ពីអ្នកនាំសារមូហាំម៉ាត់(សូមសន្តិភាពកើតមានចំពោះគាត់)ពួកគេទាំងនោះគឺ(គិតតាមលំដាប់នៃគុណសម្បត្តិនិងឋានានុក្រមនៃការគ្រប់គ្រងឃីឡាហ្វះ)៖
    1) អាពូពើការ អាសស៊ីតឌីក(ទទួលមរណភាពឆ្នាំទី១៣ ហ.ស)
    2) អូម៉ើរ កូន អាល់ខត់តប(ទទួលមរណភាពឆ្នាំទី២៣ ហ.ស)
    3) អូស្មាន កូន អ័ហ្វហ្វាន(ទទួលមរណភាពឆ្នាំទី២៥ ហ.ស)
    4) អាលី កូន អាពីតាឡិប(ទទួលមរណភាពឆ្នាំទី៤០ ហ.ស)
14. រីឯអ្នកបន្ទាប់ក្នុងចំណោមអ្នកទាំងដប់នោះគឺ ស្អ៊ូពែរ កូន អាល់អាវ៉ាម

សាអាដ កូន អាពីវ៉ាកើស តល់ហះ កូន អ៊ូបៃទិលឡោះ អាប់ឌុររ៉ស់ម៉ាន កូន អ័ហ្វ អាពូអូបៃឌះ អាមៀរ កូន អាល់ជើររ៉ស់ សាអ៊ីដ កូន សៃ្សត(អល់ឡោះបានសព្វព្រះទ័យចំពោះពួកគេព្រមទាំងពួកសហការីទាំងអស់)។

## ជំពូកទី២៤
## សីលធម៌ និងសុជីវធម៌អ៊ីស្លាម

1) អ្នកមូស្លីមទៀងត្រង់ជឿជាក់ គ្មានការភូតកុហក។
2) អ្នកមូស្លីមគោរពពាក្យសន្យា មិនមានឧបាយកលក្បត់ មានជំនឿទុកចិត្ត មិនបោកប្រាស់។
3) អ្នកមូស្លីមមិននិយាយាបងប្អូនមូស្លីមខ្លួនឯង។
4) អ្នកមូស្លីមក្លាហាន មិនកំសាក។
5) អ្នកមូស្លីមតស៊ូអត់ធ្មត់ចំពោះសច្ចធម៌ ហ៊ានពោលពាក្យពិត។
6) អ្នកមូស្លីមផ្តល់ភាពយុត្តិធម៌ដល់មនុស្សទូទៅមិនព្រឹត្តអំពើអយុត្តិធម៌
7) លើនរណាម្នាក់ ហើយក៏មិនព្រមឱ្យនរណាម្នាក់ប្រព្រឹត្តអំពើអយុត្តិធម៌មកលើខ្លួនឯងដែរ។ អ្នកមូស្លីមថ្លៃថ្នូរគ្មាននរណាម្នាក់អាចប្រមាថមើលងាយគេបានឡើយ។
8) អ្នកមូស្លីមសុំប្រឹក្សាយោបល់ចំពោះគ្រប់កិច្ចការទាំងអស់ ហើយពឹងអាស្រ័យអល់ឡោះ។
9) អ្នកមូស្លីមត្រូវម៉ត់ចង់ចំពោះការងាររបស់ខ្លួន។
10) អ្នកមូស្លីមឱនលំទោន មេត្តាករុណា ប្រើគ្នាឱ្យប្រតិបត្តិអំពើល្អហាម

11) ឃាត់គ្នាពីការប្រព្រឹត្តអំពើអាក្រក់។
12) អ្នកមូស្លីមតស៊ូដើម្បីលើកតម្កើងបន្ទូលរបស់អល់ឡោះ និងអំពាវនាវដើម្បីលើកស្ទួយសាសនាឥស្លាម។
13) ស្រ្តីមូស្លីមត្រូវស្លៀកពាក់បិទបាំងខ្លួនប្រាណជិតៗតាមច្បាប់ស្លាម នៅមុខអ្នកដែលមិនមែនជាសាច់ញាតិរបស់ខ្លួន។ ត្រូវគ្របជិតខ្លួនប្រាណទាំងមូលលើកលែងតែមុខនិងបាតដៃទាំងពីរ។

## ជំពូកទី២៥
## ការរំឭក និង ការបួងសួង

1) នៅពេលណាអ្នកចង់ហូបចុក ឬផឹក ចាំបាច់អ្នកត្រូវសូត្រថា៖ ‹‹ពីសមីលឡះ›› ‹‹ بسم الله ››
2) ហូបអាហារនឹងដៃស្តាំ មិនមែនហូបនឹងដៃឆ្វេងទេ។
3) នៅពេលអ្នករួចរាល់ពីការហូបចុកចូរអ្នកសូត្រថា៖ ‹‹អាល់ហាំឌូលីលឡះ›› ‹‹ الحمد لله ››
4) នៅពេលអ្នកបានជួបនឹងបងប្អូនអ៊ីស្លាមរបស់អ្នក អ្នកត្រូវចាប់ដៃគ្នា ហើយញញឹមដាក់គ្នា ដោយពោលថា៖ ‹‹ السلام عليكم ورحمة الله وبركاته ››
5) នៅពេលបងប្អូនអ៊ីស្លាមឱ្យសាឡាមដល់អ្នក (ពាក្យជូនពរ)ថា៖ ‹‹ السلام عليكم ورحمة الله وبركاته ›› អ្នកត្រូវតបវិញថា៖ ‹‹ وعليكم السلام ورحمة الله وبركاته ››។
6) នៅពេលថ្ងៃរះ ឬនៅពេលល្ងាច ចូរអ្នកសូត្រ៖

(أصبحنا ) ឬ( أمسينا ) على فطرة الإسلام ، وكلمة الإخلاص ، ودين نبينا محمد ، وملة أبينا إبراهيم ، حنيفا مسلما ، وما أنا من المشركين )

7) នៅពេលខ្ញើតខែថ្មីរះឡើងចូរសូត្រថា៖

( هلال خير ورشد ، اللهم أهله علينا باليمن والإمان ، والسلامة ولإسلام ).

8) នៅពេលទៅសួរសុខទុក្ខអ្នកជំងឺ ត្រូវសូត្រថា៖

(بسم الله ، اللهم أذهب البأس ، رب الناس ، اللهم اشف وأنت الشافي ، لاشفاء إلا شفاؤك ، شفاء لا يغادر سقما ).

9) នៅពេលអ្នកចូលម៉ាស្ជិត ចូរអ្នកសូត្រថា៖

( بسم الله ، والصلاة والسلام على رسو ل الله ، اللهم اغفر لي ذنوبي ، وفتح لي أبواب رحمتك )

10) នៅពេលអ្នកចាកចេញពីម៉ាស្ជិត
ចូរសូត្រដូចពេលអ្នកចូលដែរ គ្រាន់តែចុងក្រោយប្តូរថា៖

( وافتح لي أبواب فضلك )

11) នៅពេលអ្នកវិលត្រលប់មកផ្ទះវិញ ចូរសូត្រថា៖

(الحمد لله الذي أطعمنا وسقانا وآوانا ، فكم ممن لا كافي له ولا مؤوى ).

12) រៀងពេលវេលា ចូរបង្កើនការប្រតិបត្តិអំពើល្អដោយសូត្រថា៖

سبحان الله .

والحمد الله .

والله أكبر .

ولا حول ولا قوة إلا بالله .

13) ដូច្នេះដែរ ចូរបង្កើនការសាឡាវ៉ាត(ការឱ្យពរ)ដល់ព្យាការី មូហាំ ម៉ាត់ (صلى الله عليه وسلم)។ ជាពិសេសនៅពេលដែលយើងបានឮឈ្មោះរបស់គាត់ គឺយើងសូត្រថា៖ សល់ឡល់ឡាហ៊ូអាឡៃហ៊ីវ៉ាសាលឡាម(صلى الله عليه وسلم)។

## ជំពូកទី២៦
## ស្ត្រីមូស្លីម

1) ស្ត្រីក្នុងសាសនាអ៊ីស្លាមជាបងប្អូនបង្កើតរបស់បុរស។
2) ស្ត្រីជាមនុស្សដែលអល់ឡោះបានបង្កើតមកដូចបុរសដែរ។
3) ដូច្នេះនាងក៏ត្រូវបានគេអំពាវនាវឱ្យចូលអ៊ីស្លាមផងដែរ។
4) នាងក៏ត្រូវបានគេបង្គាប់ប្រើឱ្យមានជំនឿចំពោះអល់ឡោះ គោរពប្រតិបត្តិ និងស្រលាញ់ទ្រង់។
5) នាងក៏ត្រូវបានគេទាមទារឱ្យមានជំនឿចំពោះសាររបស់ព្យាការីមូហាំម៉ាត់។
6) គេទាមទាឱ្យនាងថ្វាយបង្គំ បួស(តម) បរិច្ចាគ ធ្វើហាជ្ជ និងគោរពសក្ការៈចំពោះអល់ឡោះ។
7) គេទាមទាឱ្យអនុវត្តតាមច្បាប់វិន័យអ៊ីស្លាមដូចបុរសដែរ។
8) អប់រំកូនៗរបស់នាងតាមមាគ៌ាអ៊ីស្លាម ឱ្យកូនៗស្គាល់នូវគុណធម៌ បីបាច់ថែរក្សាពួកគេ។ ស្ត្រីខុសពីបុរសដូចតទៅ៖
9) នាងត្រូវពាក់សំលៀកបំពាក់គ្របជិតរាងកាយទាំងមូលលើកលែងតែមុខ និងបាតដៃទាំងពីរ។

10) នៅពេលនាងមានរដូវ ច្បាប់អ៊ីស្លាមមិនអនុញ្ញាតឱ្យនាងថ្វាយបង្គំ បួស(តម) មិនឱ្យស្ទូត្រគម្ពីរអាល់គួរអាន មិនឱ្យចូលវិហារ (ម៉ាស្ជិត)។

11)នៅពេលនាងអស់រដូវ ចាំបាច់ត្រូវងូតទឹក និងបួស(តម)សងវិញ តែមិនចាំបាច់ថ្វាយបង្គំសងទេ។

12) មិនចាំបាច់ចំពោះស្ត្រីត្រូវចូលរួមថ្វាយបង្គំថ្ងៃសុក្រនោះទេ។

13) ច្បាប់អ៊ីស្លាមមិនអនុញ្ញាតឱ្យស្ត្រីរៀបការជាមួយបុរសណាសរ៉ានី(គ្រិស្ទាន) ឬបុរសយ៉ាហ៊ូឌី(ជីហ្វ) ឬជនកាហ្វៀរនោះទេ។ លើកលែងតែពួកគេទាំងនោះចូលអ៊ីស្លាមយ៉ាងពិតប្រាកដ ជឿជាក់ច្បាស់។

# សេចក្តីបន្ថែមទី១
# (ជំពូក១នៅក្នុងគម្ពីរអាល់គួរអាន)

## ជំពូកអាល់ហ្វាទីហះ

١- ﴿ بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ ١ ﴾

٢- ﴿ ٱلۡحَمۡدُ لِلَّهِ رَبِّ ٱلۡعَٰلَمِينَ ٢ ﴾

٣- ﴿ ٱلرَّحۡمَٰنِ ٱلرَّحِيمِ ٣ ﴾

٤- ﴿ مَٰلِكِ يَوۡمِ ٱلدِّينِ ٤ ﴾

٥- ﴿ إِيَّاكَ نَعۡبُدُ وَإِيَّاكَ نَسۡتَعِينُ ٥ ﴾

٦- ﴿ ٱهۡدِنَا ٱلصِّرَٰطَ ٱلۡمُسۡتَقِيمَ ٦ ﴾

٧- ﴿ صِرَٰطَ ٱلَّذِينَ أَنۡعَمۡتَ عَلَيۡهِمۡ غَيۡرِ ٱلۡمَغۡضُوبِ عَلَيۡهِمۡ وَلَا ٱلضَّآلِّينَ ٧ ﴾

មានន័យថា ៖

1. ‹‹ ក្នុងព្រះនាមអល់ឡោះមហាមេត្តា មហាករុណា››
2. ‹‹ ការសរសើរសម្រាប់អល់ឡោះជាព្រះជាម្ចាស់នៃសកលលោកទាំងមូល ››
3. ‹‹ ព្រះមហាមេត្តា មហាករុណា ››
4. ‹‹ ទ្រង់ជាស្តេចគ្រប់គ្រងនៃថ្ងៃកាត់ក្តី ››
5. ‹‹ ចំពោះទ្រង់តែមួយគត់ដែលពួកយើងគោរពសក្ការៈ ហើយមានតែទ្រង់តែមួយគត់ដែលពួកយើងសុំជំនួយ ››។

6. ‹‹ សូមទ្រង់មេត្តាប្រទានដល់ពួកយើងនូវមាគ៌ាដ៏ត្រឹមត្រូវ ››។
7. ‹‹ មាគ៌ាដែលទ្រង់បានប្រទានដល់ពួកអ្នកដែលទ្រង់ប្រទានពរជ័យដល់ពួកគេ មិនមែនជាមាគ៌ាពួកអ្នកដែលត្រូវគេក្រោធខឹង និងមិនមែនជាមាគ៌ាពួកដែលវង្វេង ››។

# ជំពូកអាល់អើសរី

(سورة العصر)

﴿ بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ ﴾

﴿ وَٱلۡعَصۡرِ ١ إِنَّ ٱلۡإِنسَٰنَ لَفِي خُسۡرٍ ٢ إِلَّا ٱلَّذِينَ ءَامَنُواْ وَعَمِلُواْ
ٱلصَّٰلِحَٰتِ وَتَوَاصَوۡاْ بِٱلۡحَقِّ وَتَوَاصَوۡاْ بِٱلصَّبۡرِ ٣ ﴾

មានន័យថា ៖

1. « អល់ឡោះទ្រង់បានស្បថនឹងពេលវេលា »
2. «ពិតប្រាកដណាស់មនុស្សលោកទាំងអស់ស្ថិតក្នុងភាពខាតបង់»
3. « លើកលែងតែពួកអ្នកដែលមានជំនឿចំពោះអល់ឡោះ បានប្រតិបត្តិអំពើល្អ ហើយបានផ្ដែផ្ដាំគ្នាឱ្យប្រកាន់ខ្ជាប់ការពិត និងផ្ដែផ្ដាំគ្នាឱ្យប្រកាន់ខ្ជាប់នូវការអត់ធ្មត់ »។

# ជំពូក អាល់ម៉ាអ៊ូន

(سورة الماعون)

﴿ بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ ﴾

﴿ أَرَءَيۡتَ ٱلَّذِي يُكَذِّبُ بِٱلدِّينِ ١ فَذَٰلِكَ ٱلَّذِي يَدُعُّ ٱلۡيَتِيمَ ٢ وَلَا يَحُضُّ
عَلَىٰ طَعَامِ ٱلۡمِسۡكِينِ ٣ فَوَيۡلٞ لِّلۡمُصَلِّينَ ٤ ٱلَّذِينَ هُمۡ عَن صَلَاتِهِمۡ سَاهُونَ ٥ ٱلَّذِينَ
هُمۡ يُرَآءُونَ ٦ وَيَمۡنَعُونَ ٱلۡمَاعُونَ ٧ ﴾

មានន័យថា ៖

1. « នៃមូហាំម៉ាត់តើអ្នកបានឃើញអ្នកដែលបដិសេធនឹងថ្ងៃកាត់ក្តីជំនុំជម្រះដែរឬទេ ? »។
2. «នោះគឺជាអ្នកដែលបោះបង់ក្មេងកំព្រា »។
3. « ហើយពួកគេមិនជំរុញគ្នាឱ្យឧបត្ថម្ភដល់ជនក្រីក្រ »។
4. « ហើយនរកវេលគឺសម្រាប់អ្នកដែលសាឡាត ( ថ្វាយបង្គំ )»។
5. «ពួកអ្នកដែលធ្វេសប្រហែសចំពោះពេលវេលាថ្វាយបង្គំរបស់ពួកគេ »។
6. « អ្នកដែលធ្វើអំពើល្អដើម្បីចង់ឱ្យគេឃើញ គេសរសើរប៉ុណ្ណោះ »។
7. « ហើយពួកគេរិះកំណាញ់មិនឱ្យគេខ្ចីរបស់ប្រើប្រាស់ »។

# ជំពូក អាល់អ៊ិខឡាស

(سورة الإخلاص)

﴿ بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ ﴾

﴿ قُلۡ هُوَ ٱللَّهُ أَحَدٌ ١ ٱللَّهُ ٱلصَّمَدُ ٢ لَمۡ يَلِدۡ وَلَمۡ يُولَدۡ ٣ وَلَمۡ يَكُن لَّهُۥ كُفُوًا أَحَدُۢ ٤ ﴾

មានន័យថា ៖

1. ‹‹ នែមហាំម៉ាត់ ចូរមានប្រសាសន៍ចុះថា ទ្រង់គឺអល់ឡោះជាព្រះជាម្ចាស់តែមួយគត់››។
2. ‹‹ អល់ឡោះជាទីពំនាក់អាស្រ័យនៃសត្វលោកទាំងមូល››។
3. ‹‹ ទ្រង់មិនប្រសូតបុត្រ ហើយក៏គ្មានអ្នកណាប្រសូតទ្រង់ដែរ ››
4. ‹‹ ហើយក៏គ្មាននរណាម្នាក់ប្រៀបស្មើនឹងទ្រង់ដែរ›› ។

# ជំពូក អាល់កាវសើរ

(سورة الكوثر)

﴿ بِسْمِ ٱللَّهِ ٱلرَّحْمَٰنِ ٱلرَّحِيمِ ﴾

﴿ إِنَّآ أَعْطَيْنَٰكَ ٱلْكَوْثَرَ ﴿١﴾ فَصَلِّ لِرَبِّكَ وَٱنْحَرْ ﴿٢﴾ إِنَّ شَانِئَكَ هُوَ ٱلْأَبْتَرُ ﴿٣﴾ ﴾

មានន័យថា ៖

1. ‹‹ពិតប្រាកដណាស់យើងបានប្រទានដល់អ្នក(មូហាំម៉ាត់)នូវទន្លេការសើរនៅក្នុងឋានសួគ៌››។
2. ‹‹ ដូច្នេះចូរសឡាត(ថ្វាយបង្គំ) និងសំលេះសត្វបូជាចំពោះព្រះជាម្ចាស់របស់អ្នក››។
3. ‹‹ ប្រាកដណាស់ អ្នកដែលខឹង ស្អប់ខ្ពើមចំពោះអ្នកនោះ គឺជាអ្នកដែលត្រូវផុតខកបំណង ››។

# ជំពូក អាល់ហ្វាឡាក

(سورة الفلق )

﴿ بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ ﴾

﴿ قُلۡ أَعُوذُ بِرَبِّ ٱلۡفَلَقِ ١ مِن شَرِّ مَا خَلَقَ ٢ وَمِن شَرِّ غَاسِقٍ إِذَا وَقَبَ ٣ وَمِن شَرِّ
ٱلنَّفَّٰثَٰتِ فِي ٱلۡعُقَدِ ٤ وَمِن شَرِّ حَاسِدٍ إِذَا حَسَدَ ٥ ﴾

មានន័យថា៖

1. ‹‹ នែមូហាំម៉ាត់ចូរមានប្រសាសន៍ចុះថា សូមព្រះជាម្ចាស់នៃពេលទៀបភ្លឺ សូមទ្រង់មេត្តាបញ្ចៀស ››
2. ‹‹ អំពីប្រការអាក្រក់ទាំងឡាយដែលទ្រង់បានបង្កើត ››
3. ‹‹ អំពីប្រការអាក្រក់ទាំងឡាយនៃពេលយប់ នៅពេលភាពងងឹតមកដល់ ››
4. ‹‹ អំពីប្រការអាក្រក់ទាំងឡាយរបស់ស្ត្រីមន្តអាគម ដែលសូត្រផ្លុំក្នុងខ្សែកថា ››
5. ‹‹ អំពីប្រការអាក្រក់ទាំងឡាយរបស់ពួកអ្នកដែលឈ្នានីស នៅពេលគេច្រណែន ››។

# ជំពូក អាន់ណាស

(سورة الناس)

﴿ بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ ﴾

﴿ قُلۡ أَعُوذُ بِرَبِّ ٱلنَّاسِ ١ مَلِكِ ٱلنَّاسِ ٢ إِلَٰهِ ٱلنَّاسِ ٣ مِن شَرِّ
ٱلۡوَسۡوَاسِ ٱلۡخَنَّاسِ ٤ ٱلَّذِي يُوَسۡوِسُ فِي صُدُورِ ٱلنَّاسِ ٥ مِنَ ٱلۡجِنَّةِ
وَٱلنَّاسِ ٦ ﴾

មានន័យថា ៖

1. ‹‹ នែមូហាំម៉ាត់ ចូរមានប្រសាសន៍ចុះថា ខ្ញុំសុំពីព្រះជាម្ចាស់នៃមនុស្សលោក ››
2. ‹‹ ជាស្តេចគ្រប់គ្រងមនុស្សលោក ››
3. ‹‹ ជាព្រះជាម្ចាស់ដែលមនុស្សលោកទាំងអស់ត្រូវគោរពសក្ការៈ ››
4. ‹‹ សូមមេត្តាទ្រង់កំបាំងពីការពង្វក់របស់ព្រាយបិសាចទាំងឡាយដែលលាក់ខ្លួន ››
5. ‹‹ ដែលកំពុងតែពង្វក់ក្នុងចិត្តរបស់មនុស្សលោក ››
6. ‹‹ ព្រាយបិសាចទាំងនោះគឺមកពីជិន និងមនុស្ស ››។

# សេចក្ដីបន្ថែមទី២
# អាត់តាស្ហះហ៊ុដ

( التشهد )

١. التحيات لله ، والصلوات والطيبات ،

٢. السلام عليك أيها النبي ورحمة الله وبركاته ،

٣. السلام علينا وعلى عباد الله الصالحين ،

٤. أشهد أن لا إله إلا الله ،

٥. وأشهد أن محمدا رسوله .

មានន័យថា ៖

1. « រាល់ការគោរពសក្ការៈ ពរជ័យ និងសេចក្ដីល្អទាំងឡាយសម្រាប់អល់ឡោះជាម្ចាស់តែមួយគត់ »។
2. « បពិត្រព្យាការីមូហាំម៉ាត់ សូមភាពសុខសាន្ត ការប្រោសប្រណីមេត្តា ការឱ្យពររបស់អល់ឡោះកើតមានចំពោះលោក »។
3. « ភាពសុខសាន្តកើតមានចំពោះយើង និងខ្ញុំបំរើអល់ឡោះដែលប្រកបដោយកុសលធម៌»។
4. « ខ្ញុំសូមសច្ចាថា គ្មានព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈយ៉ាងពិតប្រាកដ លើកលែងតែអល់ឡោះតែមួយគត់ »។
5. « ហើយខ្ញុំសូមធ្វើសច្ចាថា មូហាំម៉ាត់ជាអ្នកនាំសាររបស់អល់ឡោះ »។

# សឡាវ៉ាត(ជូនពរ)តាមព្យាការីអ៊ីព្រហ៊ីម

១. اللهم صل على محمد ،
២. وعلى آل محمد ،
៣. كما صليت على إبراهيم ،
៤. وعلى آل إبراهيم ،
៥. وبارك على محمد ،
៦. وعلى آل محمد
៧. كما باركت على إبراهيم ،
៨. وعلى آل إبراهيم ،
៩. في العالمين ،
១០. إنك حميد مجيد .

មានន័យថា ៖

1. ‹‹ បពិត្រអល់ឡោះ សូមទ្រង់ប្រទានពរជ័យសិរីសួស្តីកើតមានដល់មូហាំម៉ាត់ ››។
2. ‹‹ និងដល់គ្រួសាររបស់គាត់ ››។
3. ‹‹ ដូចជាទ្រង់បានប្រទានពរជ័យសិរីសួស្តីកើតមានដល់អ៊ីព្រហ៊ីម››។
4. ‹‹ និងដល់គ្រួសារអ៊ីព្រហ៊ីម ››។
5. ‹‹ សូមទ្រង់ទ្រង់ប្រសិទ្ធិពរដល់មូហាំម៉ាត់ ››។
6. ‹‹ និងដល់គ្រួសារអ៊ីព្រហ៊ីម ››។
7. ‹‹ ដូចដែលទ្រង់បានប្រសិទ្ធិពរដល់អ៊ីព្រហ៊ីម ››។
8. ‹‹ និងដល់គ្រួសារអ៊ីព្រហ៊ីម ››។
9. ‹‹លើសសកលលោកទាំងមូល ››។
10. ‹‹ ពិតណាស់អល់ឡោះមហាមេត្តា និងមហាឧត្តុង្គឧត្តម ››។

قَالَ اللهُ عَزَّ وَجَلَّ :

﴿ فَمَن يُرِدِ ٱللَّهُ أَن يَهۡدِيَهُۥ يَشۡرَحۡ صَدۡرَهُۥ لِلۡإِسۡلَٰمِۖ ﴾

បន្ទូលអល់ឡោះ

“អ្នកណាដែលអល់ឡោះសព្វព្រះទ័យឱ្យគេទទួលបាន
នូវសេចក្តីចង្អុលបង្ហាញ គឺទ្រង់បើកដួងចិត្តរបស់គេ
ឱ្យយល់ពីអ៊ីស្លាម”


អង្គការវប្បធម៌ អារ្យធម៌កម្ពុជា_អារ៉ាប់
Cambodia Arab Cultural Civilizational Organization

សមាគមសប្បុរសធម៌ដើម្បីអភិវឌ្ឍន៍កម្ពុជា
CAMBODIAN AL-BARAKAH CHARITABLE ASSOCIATION